# ច្បាប់

# ស្ដីពីប្រតិបត្តិ

# ការដែលមាន

# កិច្ចធានា

# ២០០៧

# ព្រះរាជក្រម

នស/រកម/០៥០៧/០១២

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពី ប្រតិបត្តិការដែលមានកិច្ចធានា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៦ ខែ មេសា ឆ្នាំ ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៣ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

១-ច្បាប់នេះមានគោលបំណងលើកស្ទួយសកម្មភាពសេដ្ឋកិច្ច តាមរយៈវិធានរួមស្តីពីការប្រើប្រាស់ទ្រព្យធានា ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ ដើម្បីធានាកាតព្វកិច្ច ។

២-ក្នុងករណីមានភាពផ្ទុយគ្នា រវាងបទប្បញ្ញត្តិនៃច្បាប់នេះ និងបទប្បញ្ញត្តិនៃច្បាប់ដទៃទៀត ច្បាប់នេះត្រូវចាត់ទុកជាបញ្ញត្តិគោល លើកលែងតែច្បាប់ផ្សេងនោះចែងយ៉ាងជាក់លាក់ ឬធ្វើវិសោធនកម្មលើបទប្បញ្ញត្តិ ដែលផ្ទុយនឹងច្បាប់នេះ ។

ចំពោះបញ្ញត្តិដែលពុំមានចែងក្នុងច្បាប់នេះទេ ត្រូវអនុវត្តតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

១-ច្បាប់នេះអនុវត្តចំពោះ :

ក-រាល់ប្រតិបត្តិការដែលមានអានុភាពលើការធានាកាតព្វកិច្ចដោយទ្រព្យធានា ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ រួមមានការបញ្ចាំចលនវត្ថុ ការផ្ទេរកម្មសិទ្ធិ បញ្ញើទុកលក់ អនុប្បទានសិទ្ធិជាដើម ។

ខ-ការលក់គណនី និងកិច្ចសន្យាលក់ដែលមានកិច្ចធានា ។

គ-ការជួលទំនិញសម្រាប់រយៈពេលលើសពីមួយឆ្នាំ ។

២-ការអនុវត្តន៍ចំពោះប្រតិបត្តិការ ដែលបានកំណត់ក្នុងចំណុចទី ១ ដោយមិនគិតពីទម្រង់ ឬពាក្យពេចន៍ ដែលប្រើក្នុងកិច្ចព្រមព្រៀងឡើយ ហើយទោះបីជាសិទ្ធិលើកម្មសិទ្ធិត្រូវបានកាន់កាប់ដោយម្ចាស់បំណុលដែលមានកិច្ចធានា ឬកូនបំណុលក៏ដោយ ។

៣-ច្បាប់ទាំងឡាយដែលចែងពីសមត្ថភាពចុះកិច្ចសន្យា ដូចជាច្បាប់ស្តីពីទីភ្នាក់ងារការឆបោក ការបន្លំតបន្លំ ការភ័ន្តច្រឡំនិងធនក្ស័យ ត្រូវបំពេញបន្ថែមលើច្បាប់នេះ ។

៤-ថ្វីបើមានចែងក្នុងចំណុចទី ១ និងចំណុចទី ២ នៃមាត្រានេះក្តី ច្បាប់នេះមិនអនុវត្ត

ក-ការផ្ទេរសិទ្ធិទាមទារប្រាក់បៀវត្សរ៍របស់និយោជិត ។

ខ-ការលក់គណនី ឬកិច្ចសន្យាលក់ ដែលមានកិច្ចធានាដែលជាផ្នែកនៃការលក់អាជីវកម្មរួមទាំងគណនី ឬកិច្ចសន្យាលក់ដែលមានកិច្ចធានានេះ ។

គ-អនុប្បទានគណនី កិច្ចសន្យាលក់ដែលមានកិច្ចធានា ឬ លិខិតស្នាមដែលសម្រាប់តែគោលបំណងប្រមូលប្រាក់ដែលជំពាក់ ។

ឃ-ការផ្ទេរសិទ្ធិទទួលប្រាក់តាមកិច្ចសន្យាទៅអនុប្បទានិក ដែលមានកាតព្វកិច្ចអនុវត្តកិច្ចសន្យា ។

ង-ការប្រាក់លើប្រាក់បញ្ញើ គណនីមូលប្បទានប័ត្រ គណនីសញ្ញ័យ សៀវភៅធនាគារ ឬគណនីសាច់ប្រាក់ដទៃទៀត លើកលែងតែផលនៃទ្រព្យធានា ។

**មាត្រា ៣.-**

នៅក្នុងច្បាប់នេះពាក្យបច្ចេកទេសទាំងឡាយ ត្រូវមានន័យដូចកំណត់ខាងក្រោម ៖

១-"កសិផល" មានន័យថា ទំនិញរបស់កូនបំណុល ដែលបានពីមុខរបរកសិកម្ម លើកលែងតែឈើឈរ ។ កសិផលរួមមាន ៖

ក-ផលដំណាំដែលដាំដុះ កំពុងដុះលូតលាស់ ឬ ផលដំណាំដែលត្រូវដាំដុះ

ខ-ទំនិញជលផលដែលផលិតក្នុងប្រតិបត្តិការវារីវប្បកម្ម

គ-សត្វចិញ្ចឹមគ្រប់ប្រភេទ រាប់ទាំងកូនសត្វដែលកើតហើយ ឬ មិនទាន់កើតផងដែរ

ឃ-ទំនិញផ្គត់ផ្គង់ដែលប្រើ ឬផលិតក្នុងប្រតិបត្តិការកសិកម្ម

ង-ផលដំណាំដែលប្រមូលបាន ឬ ផលដែលបានមកពីសត្វចិញ្ចឹមគ្រប់ប្រភេទ ហើយមិនទាន់កែច្នៃ ។

២-"ការជួលទំនិញសម្រាប់រយៈពេលលើសពីមួយ(០១)ឆ្នាំ" មានន័យថា ៖

ក-ការជួលទំនិញដែលកំណត់រយៈពេលលើសពីមួយ(០១)ឆ្នាំ ។

ខ-ការជួលទំនិញដែលគ្មានកំណត់រយៈពេល ទោះបីជារយៈពេលនេះអាចត្រូវបានកំណត់ថាតិចជាងមួយឆ្នាំក៏ដោយ ។

គ-ការជួលទំនិញដែលកំណត់រយៈពេលដំបូងមួយឆ្នាំ ឬតិចជាងមួយឆ្នាំ បើអ្នកជួលបន្តកាន់កាប់ទំនិញដោយបានការឯកភាពពីអ្នកជួលឱ្យនិងគ្មានការអាក់ខាន ឬ គ្មានការអាក់ខានជាសារវន្ត ក្នុងរយៈពេលមួយ(០១)ឆ្នាំ បន្ទាប់ពីអ្នកជួលបានទទួលចលនវត្ថុនោះមក ប៉ុន្តែកិច្ចសន្យាជួលនេះ មិនក្លាយទៅជាមានរយៈពេលមួយ(០១)ឆ្នាំទេ លើកលែងតែអ្នកជួលបន្តការកាន់កាប់លើសពីមួយ(០១)ឆ្នាំ

ឃ-ការជួលទំនិញដែលកំណត់រយៈពេលមួយ(០១)ឆ្នាំ ឬ តិចជាងមួយ(០១)ឆ្នាំ កាលណាកិច្ចសន្យាជួលចែងថា អាចបន្តរយៈពេលលើសពីមួយ(០១)ឆ្នាំ ។

៣-"ការទិញ" ការទទួលបានវត្ថុក្នុងឋានៈជាអ្នកទិញ រាប់បញ្ចូលទាំងអ្នកទទួលអំណោយ អ្នកទទួលទ្រព្យធានា ម្ចាស់បំណុលដែលមានកិច្ចធានា ឬ ម្ចាស់បំណុលអ៊ីប៉ូតែក ឬ តាមប្រតិបត្តិការដោយស្ម័គ្រចិត្តដែលបង្កើតសិទ្ធិលើទ្រព្យ ។ បុគ្គលដែលទទួលបានចលនវត្ថុដោយការទិញហៅថា "អ្នកទិញ" ។

៤-"បញ្ជាក់ការឯកភាព" មានន័យថា ការចុះហត្ថលេខា ឬ ការឯកភាពលើឈ្មោះ ឬ និមិត្តសញ្ញាផ្សេងៗ ដែលធ្វើឡើងដោយផ្ទាល់ដៃ ឬ តាមវិធីផ្សេងៗ ហើយមានគោលបំណងបញ្ជាក់ពីអត្តសញ្ញាណរបស់ភាគីដែលឯកភាព ឬ ផ្តល់ការឯកភាព ឬ បញ្ជាក់ឱ្យកំណត់ត្រាមានតម្លៃតាមច្បាប់ ។

៥-"កិច្ចធានា" គឺជាកាតព្វកិច្ចគាំទ្រ ជាអាទិ៍មានកាតព្វកិច្ចបង់ប្រាក់ ឬកាតព្វកិច្ចបង់ប្រាក់របស់អ្នកចេញលិខិតឥណទាន និងដែលគាំទ្រការបង់ប្រាក់ ឬការបំពេញកាតព្វកិច្ចលើកណនី កិច្ចសន្យាលក់ដែលមានកិច្ចធានា ឯកសារ លិខិតស្នាម ឬ ទ្រព្យអរូបីដទៃទៀត ។

៦-"កិច្ចសន្យាលក់ដែលមានកិច្ចធានា" មានន័យថា កំណត់ត្រាដែលបង្កើតកាតព្វកិច្ចបង់ប្រាក់ និងសិទ្ធិប្រាតិភោគលើទំនិញ ឬ ការជួលទំនិញ ។

៧-"កិច្ចព្រមព្រៀងប្រាតិភោគ" គឺជាកិច្ចព្រមព្រៀងដែលបង្កើត ឬ ចែងពីសិទ្ធិប្រាតិភោគ ។

៨-"ក្ខនបំណុល" មានន័យថា បុគ្គលដែលជំពាក់ប្រាក់ ឬកាតព្វកិច្ច ទោះបុគ្គលនេះជាកម្មសិទ្ធិករ ឬបុគ្គលដែលមានសិទ្ធិលើទ្រព្យធានាក៏ដោយ និងរាប់បញ្ចូលទាំងអ្នក

៥

លក់គណនី ឬ កិច្ចសន្យាលក់ដែលមានកិច្ចធានា អ្នកទទួលទំនិញទុកលក់ អ្នកជួលចលនវត្ថុតាមកិច្ចសន្យាជួលដែលកំណត់ក្នុងច្បាប់នេះ ។

៩-"កូនបំណុលគណនី" មានន័យថា បុគ្គលដែលជំពាក់កាតព្វកិច្ចក្នុងគណនីក្នុងកិច្ចសន្យាលក់ដែលមានកិច្ចធានា ឬ ទ្រព្យអរូបីដទៃទៀត ។

១០-"កំណត់ត្រា" គឺជាព័ត៌មានដែលកត់ត្រាតាមមធ្យោបាយទាក់ទងរូបី ឬ ព័ត៌មានដែលរក្សាទុកក្នុងប្រព័ន្ធអេឡិចត្រូនិក ឬ មធ្យោបាយទាក់ទងផ្សេងទៀត និងអាចយកមកប្រើបានក្នុងទម្រង់ដែលអាចយល់ ឬដឹងខ្លឹមសារបាន ។ លិខិតជូនដំណឹង វិសោធនកម្ម លិខិតស៊ុំបន្ត ឬ លិខិតស៊ុំបញ្ចប់ត្រូវចាត់ទុកជាកំណត់ត្រា បើបានប្រគល់ជូនការិយាល័យតម្កល់តាមមធ្យោបាយដែលការិយាល័យតម្កល់បានកំណត់ ។

១១-"គណនី" គឺជាសិទ្ធិទទួលការទូទាត់ថ្លៃទំនិញដែលបានលក់ ឬ បានជួល ឬ ថ្លៃសេវាកម្មដែលមិនមែនជាលិខិតស្នាម ឬ កិច្ចសន្យាលក់ដែលមានកិច្ចធានា ។

១២-"គាហកនៃសិទ្ធិឃាត់ទុក" មានន័យថា :

ក-បុគ្គលដែលទទួលបានសិទ្ធិ លើទ្រព្យធានារបស់ម្ចាស់បំណុលមានកិច្ចធានា ឬ មានសិទ្ធិរឹបអូសទ្រព្យធានារបស់ម្ចាស់បំណុល ដែលមានកិច្ចធានាតាមវិធីប្តឹងទៅមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ដូចជាមន្ត្រីតុលាការ អភិបាល ឬ អភិបាលបណ្តោះអាសន្នក្នុងរឿងក្តីក្ស័យធនជាដើម ។

ខ-បុគ្គលដែលមានឯកសិទ្ធិទូទៅ ឬ ឯកសិទ្ធិលើចលនវត្ថុពិសេសតាមច្បាប់ផ្សេងទៀត ។

១៣-"ចលនវត្ថុតាំងភ្ជាប់" គឺជាទំនិញដែលបានភ្ជាប់ទៅនឹងអចលនវត្ថុ ឬ មានគោលបំណងតាំងភ្ជាប់ទៅនឹងអចលនវត្ថុ តាមរបៀបមួយដែលនាំឱ្យមានសិទ្ធិប្រស្ព័ក្យកើតឡើងតាមច្បាប់ភូមិបាលជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

១៤-"តម្លៃ" មានន័យថាតម្លៃដែលបានផ្តល់សម្រាប់សិទ្ធិក្នុងករណីដែលបុគ្គលបានទទួលសិទ្ធិ :

ក-ជាថ្នូរនឹងការសន្យាមានសុពលភាពក្នុងការផ្តល់ឥណទាន ទោះបីជាការសន្យាដែលអាចដកវិញបាន ឬ មិនអាចដកវិញបានក៏ដោយ ។

ខ-ជាទ្រព្យធានា ឬ ការទូទាត់ទាំងស្រុង ឬ មួយភាគចំពោះការទាមទារពីមុន ។

គ-ដោយការទទួលការប្រគល់ អនុលោមតាមកិច្ចសន្យាទិញដែលមានស្រាប់ ។

ឃ-ជាថ្នូរនឹងអ្វីដែលត្រូវបានផ្តល់ក្នុងការដោះដូរ ឬជាថ្នូរនឹងការសន្យា។

១៥-"ទំនិញ" គឺជាវត្ថុដែលជាចលនវត្ថុក្នុងពេលដែលសិទ្ធិប្រាតិភោគភ្ជាប់ទៅនឹងវត្ថុនេះ ។ ក្នុងនេះពាក្យថា ទំនិញសំដៅដល់ផលិតផលរ៉ែ ដែលត្រូវភ្ជាប់សិទ្ធិប្រាតិភោគនៅពេលជីកបាន ឈើឈរដែលបំរុងនឹងកាប់ កូនសត្វចិញ្ចឹមគ្រប់ប្រភេទមិនទាន់កើតនិងផលដំណាំដែលបានដាំដុះ កំពុងលូតលាស់ ឬដែលត្រូវដាំដុះ រាប់បញ្ចូលទាំងផលដំណាំនៅជាប់នឹងដើម ប្រេង ជ័រ ឬរុក្ខជាតិផងដែរ ។ ពាក្យថា ទំនិញនេះមិនរាប់បញ្ចូលនូវគណនីកិច្ចសន្យាលក់ដែលមានកិច្ចធានា រូបិយវត្ថុ ឯកសារ ឬ លិខិតស្នាមឡើយ ។

១៦-"ទំនិញប្រើប្រាស់" គឺទំនិញដែលបានប្រើប្រាស់ ឬទិញសម្រាប់ប្រើប្រាស់ជាចម្បងសម្រាប់គោលបំណងផ្ទាល់ខ្លួន សមាជិកគ្រួសារ ឬសម្រាប់គោលបំណងគ្រួសារ ទំនិញទាំងនេះ មិនអាចជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគបានទេ លើកលែងតែយានយន្តមានលេខស៊េរី ។

១៧-"ទំនិញបញ្ចូលគ្នា" មានន័យថាទំនិញដែលបានលាយបញ្ចូលជាមួយទំនិញផ្សេងតាមរបៀបមួយដែលអត្តសញ្ញាណនៃទំនិញនេះត្រូវបាត់បង់និងចូលក្នុងទំនិញថ្មី ឬក្នុងសមាសធាតុរួម ។

១៨-"ទ្រព្យអរូបីផ្សេងទៀត" មានន័យថារាល់ចលនវត្ថុ ឬសិទ្ធិដែលក្រៅពីទំនិញ គណនី កិច្ចសន្យាលក់ដែលមានកិច្ចធានា ឯកសារ លិខិតស្នាម និងរូបិយវត្ថុ ។

១៩-"បញ្ញើទុកលក់" គឺជាប្រតិបត្តិការដែលបុគ្គលម្នាក់(អ្នកផ្ញើទំនិញទុកលក់) ប្រគល់ទំនិញឱ្យទៅពាណិជ្ជករ(អ្នកទទួលទំនិញទុកលក់) ដើម្បីលក់ដោយមិនគិតពីទម្រង់នៃកិច្ចសន្យា ឬពាក្យពេចន៍ដែលប្រើក្នុងកិច្ចសន្យាហើយ:

ក-ពាណិជ្ជករទិញនិងលក់ទំនិញប្រភេទនេះ ប្រើឈ្មោះផ្សេងពីឈ្មោះអ្នកផ្ញើទំនិញទុកលក់ ។

ខ-ពាណិជ្ជករមិនមែនជាអ្នកលក់ដេញថ្លៃ ។

គ-ទំនិញមិនមែនជាទំនិញប្រើប្រាស់ មុនពេលប្រគល់ឱ្យទៅពាណិជ្ជករ ។

ឃ-ប្រតិបត្តិការនេះមិនបង្កើតសិទ្ធិប្រាតិភោគ ដែលធានាកាតព្វកិច្ច នោះទេ ។

២០-"បុគ្គល" មានន័យថារូបវន្តបុគ្គល ឬនីតិបុគ្គលដែលច្បាប់កម្ពុជាទទួលស្គាល់ ។

២១-"អ្នកទិញក្នុងអាជីវកម្មធម្មតា" មានន័យថា បុគ្គលដែលទិញទំនិញពីបុគ្គលដែលប្រកបអាជីវកម្មលក់ទំនិញ ក្នុងប្រភេទទំនិញដែលបានទិញ បើអ្នកទិញបានទិញដោយសុចរិត ហើយមិនបានដឹងថាការលក់នេះបំពានលើសិទ្ធិរបស់បុគ្គលផ្សេងទេ ។

២២-"ផលនៃទ្រព្យធានា" មានន័យថា អ្វីដែលទទួលបាននៅពេលលក់ ជួល ឬផ្តល់អាជ្ញាប័ណ្ណ ដោះដូរ ឬការជម្រះចោលទ្រព្យធានាតាមវិធីផ្សេងពីនេះ ។ គឺអ្វីៗដែលប្រមូលបានពីទ្រព្យធានា អ្វីៗត្រូវបានបែងចែកពីទ្រព្យធានា ដូចជាសិទ្ធិដែលផុសចេញពីទ្រព្យធានា បណ្តឹងទាមទារដែលកើតចេញពីការខាតបង់ ការមិនគោរពតាមវិការៈ ឬការខូចខាតទ្រព្យធានា ទៅតាមកំរិតតម្លៃនៃទ្រព្យធានា ថ្លៃធានារ៉ាប់រងដែលត្រូវសងដោយសារការខាតបង់ ឬ ការមិនគោរពតាមវិការៈ ឬការខូចខាតទ្រព្យធានា ទៅតាមកំរិតតម្លៃទ្រព្យធានា និងតាមកំរិតដែលត្រូវចេញសងកូនបំណុល ឬម្ចាស់បំណុលដែលមានកិច្ចធានា ។ "ផលជារូបិយវត្ថុ" មានន័យថា ផលជាសាច់ប្រាក់ មូលប្បទានប័ត្រ មូលនិធិដែលផ្ញើក្នុងធនាគារ និងផលនៃទ្រព្យធានា ដែលមានលក្ខណៈដូចគ្នានេះ ។

២៣-"ម្ចាស់បំណុលដែលមានកិច្ចធានា" មានន័យថា អ្នកឱ្យខ្ចី អ្នកលក់ ឬបុគ្គលដែលទទួលសិទ្ធិប្រាតិភោគ តាមកិច្ចសន្យាប្រាតិភោគ រាប់បញ្ចូលទាំងបុគ្គលដែលបានទិញគណនី ឬកិច្ចសន្យាលក់ដែលមានកិច្ចធានា អ្នកផ្ញើទំនិញទុកលក់ និងអ្នកជួលឱ្យដែលជួលទំនិញតាមការកំណត់នៃច្បាប់នេះ ។

២៤-"ម្ចាស់បំណុលក្នុងលិខិតជូនដំណឹង" គឺជាបុគ្គលដែលដាក់ឈ្មោះជាម្ចាស់បំណុលដែលមានកិច្ចធានា ឬ តំណាងរបស់ម្ចាស់បំណុលមានកិច្ចធានា ក្នុងលិខិតជូនដំណឹងដំបូង ឬវិសោធនកម្មដែលបានតម្កល់ ។ បុគ្គលនេះមានឋានៈជាម្ចាស់បំណុលដែលមានកិច្ចធានាក្នុងលិខិតជូនដំណឹង ក្នុងរយៈពេលតម្កល់ ឬរហូតដល់ពេលបានតម្កល់វិសោធនកម្មដែលលុបឈ្មោះម្ចាស់បំណុលនេះ ឬ រហូតដល់ពេលលិខិតសុំបញ្ចប់សិទ្ធិប្រាតិភោគ

របស់ម្ចាស់បំណុលក្នុងលិខិតជូនដំណឹង ឬ រហូតដល់ពេលដែលលិខិតជូនដំណឹងទាក់ទិននឹងម្ចាស់បំណុលមានកិច្ចធានា ផុតរយៈពេលកំណត់ ។

២៥-"យានយន្តមានលេខសេរី" មានន័យថា យានយន្ត រថសណ្តោង អាកាសយាន កាណូត ឬទូកដែលមានម៉ាស៊ីន បើយានយន្តទាំងនេះមិនមែនជាសារពើភណ្ឌរបស់កូនបំណុល ។

២៦-"លិខិតស្នាម" គឺជាកំណត់ត្រាដែលបង្ហាញភស្តុតាងពីសិទ្ធិទទួលប្រាក់ដែលមិនមែនជាកិច្ចព្រមព្រៀងប្រាតិភោគ ឬ កិច្ចសន្យាជួល និងការផ្ទេរមួយប្រភេទដែលកើតឡើងតាមការប្រគល់ក្នុងអាជីវកម្មធម្មតាដោយមានបិដ្ឋិលេខចំណារខ្នង ឬ អនុប្បទានសិទ្ធិ ។ ពាក្យនេះរាប់បញ្ចូលទាំងភស្តុតាងនៃសិទ្ធិប្រាតិភោគផងដែរ ។

២៧-"លិខិតជូនដំណឹង" គឺជាកំណត់ត្រាដែលបានតម្កល់ ឬ ដាក់ជូនដើម្បីតម្កល់នៅការិយាល័យតម្កល់ ។ ពាក្យនេះរាប់បញ្ចូលទាំងវិសោធនកម្ម លិខិតសុំបន្ត និងលិខិតសុំបញ្ចប់ដែលបានតម្កល់ ឬ ដាក់ជូនដើម្បីតម្កល់ ។

២៨-"វត្ថុចំណុះ" សំដៅដល់ចលនទ្រព្យដែលបានផ្គុំបញ្ចូលជាមួយចលនវត្ថុផ្សេង តាមរបៀបដែលមិនធ្វើឱ្យបាត់បង់អត្តសញ្ញាណនៃចលនវត្ថុចម្បងនោះទេ ។

២៩-"សារពើភណ្ឌ" គឺជាទំនិញដែលបុគ្គលកាន់កាប់សម្រាប់លក់ ជួល ឬ ជាវត្ថុធាតុដើម គំរោងដែលកំពុងដំណើរការ សម្ភារៈដែលប្រើប្រាស់ក្នុងអាជីវកម្ម ។

៣០-"សិទ្ធិប្រាតិភោគលើប្រាក់ខ្ចីទិញ" មានន័យថាសិទ្ធិប្រាតិភោគដែល :

ក-ត្រូវបានយក ឬ រក្សាទុកដោយអ្នកលក់ទំនិញដើម្បីធានាតម្លៃទំនិញនោះទាំងស្រុង ឬ មួយផ្នែក

ខ-ត្រូវបានយកដោយបុគ្គល ក្រៅពីអ្នកលក់ដែលបានបង់តម្លៃ ដើម្បីឱ្យកូនបំណុលទទួលបានសិទ្ធិ ឬការប្រើប្រាស់ទំនិញតាមរយៈការបង្កើតកាតព្វកិច្ច បើតម្លៃនោះ បានប្រើតាមគោលបំណងនេះប្រាកដមែន ។

៣១-"អនុប្បទានសិទ្ធិ" គឺជាការផ្ទេរពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់នូវសិទ្ធិទាំងស្រុង ឬមួយផ្នែកលើគណនី កិច្ចសន្យាលក់ដែលមានកិច្ចធានា ឯកសារ លិខិតស្នាម ឬសិទ្ធិទទួលការបង់ប្រាក់ផ្សេងទៀត ។

បុគ្គលដែលផ្ទេរសិទ្ធិនេះហៅថា អនុប្បទាយី និងបុគ្គលដែលទទួលសិទ្ធិផ្ទេរហៅថា អនុប្បទានិក ។

៣២-"អ្នកជួលក្នុងអាជីវកម្មធម្មតា" គឺជាបុគ្គលដែលបានជួលទំនិញតាមប្រភេទនៃទំនិញក្នុងអាជីវកម្មពីបុគ្គលដែលមានអាជីវកម្មលក់ ឬ ជួលទំនិញធម្មតាដោយសុចរិតនិងមិនដឹងថាការជួលនេះបំពានលើសិទ្ធិកម្មសិទ្ធិ ឬ សិទ្ធិប្រាតិភោគ ឬ សិទ្ធិរបស់តតិយជនលើទំនិញនេះឡើយ ។ "កិច្ចសន្យាលក់បណ្តាក់" អាចធ្វើឡើងជាថ្នូរនឹងរូបិយវត្ថុ ឬទ្រព្យផ្សេងទៀត ។

៣៣-"ឧបករណ៍" មានន័យថា ទំនិញ លើកលែងតែកសិផល សារពើភណ្ឌ ទំនិញប្រើប្រាស់ ឬយានយន្តមានលេខស៊េរី ។

៣៤-"ឯកសារ" មានន័យថា ប័ណ្ណកម្មសិទ្ធិ ឬបង្កាន់ដៃ ជាអាទិ៍មានប័ណ្ណដឹកជញ្ជូន សក្ខីប័ត្រកំពង់ផែ បង្កាន់ដៃឃ្លាំង ដែលចេញដោយបុគ្គលដែលធ្វើអាជីវកម្មដឹកជញ្ជូន ឬ ស្តុកទំនិញ ។

**មាត្រា ៤.-**

១-សិទ្ធិប្រាតិភោគ គឺជាសិទ្ធិប្រត្យ័ក្សលើទ្រព្យធានា ដែលដាក់ធានាការបំពេញកាតព្វកិច្ច ។

២-បុគ្គលគ្រប់រូបអាចផ្តល់ ឬ ទទួលសិទ្ធិប្រាតិភោគ ដែលមានចែងក្នុងច្បាប់នេះ លើកលែងតែប្រការដែលមានចែងក្នុងចំណុចទី ៣ នៃមាត្រានេះ ។

៣-មិនអាចបង្កើតសិទ្ធិប្រាតិភោគលើទំនិញប្រើប្រាស់បានទេ លើកលែងតែសិទ្ធិប្រាតិភោគលើប្រាក់ទិញលើទំនិញរបស់កូនបំណុល ។

៤-មិនអាចចាត់ទុកថា សិទ្ធិប្រាតិភោគគ្មានសុពលភាពទេ បើកូនបំណុលមានសិទ្ធិប្រើប្រាស់ កាន់កាប់ លក់ ដោះដូរ បញ្ចូលគ្នា ឬ ជម្រះចោលទ្រព្យធានា ។

**មាត្រា ៥.-**

១-សិទ្ធិប្រាតិភោគអាចធានាកាតព្វកិច្ចមួយ ឬ ច្រើន ដែលចែងជាក់លាក់ ឬ ប្រើពាក្យទូទៅបាន ។

២-កាតព្វកិច្ចប្រាតិភោគជាកាតព្វកិច្ចជារូបិយវត្ថុ ឬ មិនមែនជារូបិយវត្ថុ ។

៣-កាតព្វកិច្ចប្រាតិភោគ ត្រូវគ្រប់គ្រងដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ឬ ច្បាប់របស់បរទេស ទោះបីជាក្នុងករណីណាមួយក៏ដោយ បទប្បញ្ញត្តិនៃច្បាប់នេះក៏ត្រូវអនុវត្តផងដែរ ។

៤-សិទ្ធិប្រាតិភោគអាចធានាកាតព្វកិច្ចអនាគតបាន ទោះបីជាកាតព្វកិច្ចជាក់លាក់ ឬកាតព្វកិច្ចមានលក្ខខណ្ឌ និងកាតព្វកិច្ចតាមជំរើសក៏ដោយ ។

៥-តាមការព្រមព្រៀងរបស់ភាគី សិទ្ធិប្រាតិភោគអាចធានាបុរេកាតព្វកិច្ចបាន ។

មាត្រា ៦.-

១-ទ្រព្យធានាអាចជាទំនិញ និងចលនវត្ថុគ្រប់ប្រភេទបាន ។

២-ទ្រព្យធានាអាចជាទ្រព្យអរូបី ជាអាទិ៍មានសិទ្ធិប្រស្ន័យ សិទ្ធិលើបំណុលនិងទ្រព្យអរូបីផ្សេងទៀត ។

៣-ទ្រព្យធានាអាចជាចលនវត្ថុតាំងភ្ជាប់ ។

៤-ទ្រព្យធានាអាចជាទ្រព្យដែលមានក្នុងពេលបច្ចុប្បន្ន ឬ អាចកើតឡើងនាពេលអនាគត ។

៥-ទ្រព្យធានាអាចស្ថិតនៅទីណាក៏បាន ទោះបីនៅក្នុង ឬនៅក្រៅព្រះរាជាណាចក្រកម្ពុជាក៏ដោយ ។

៦-ទ្រព្យធានាអាចជាគណនី និងកិច្ចសន្យាលក់ដែលមានកិច្ចធានាដែលបានលក់ ទំនិញដែលបានធ្វើទុកលក់ ទំនិញដែលបានជួលហើយនិងផលនៃទ្រព្យធានា ។

៧-សេចក្តីអធិប្បាយពីទ្រព្យធានាត្រូវចាត់ទុកថាគ្រប់គ្រាន់ បើក្នុងសេចក្តីអធិប្បាយនោះមានបញ្ជាក់សមស្របពីអត្តសញ្ញាណទ្រព្យធានា ។ សេចក្តីអធិប្បាយពីទ្រព្យធានាអាចចែងជាពាក្យទូទៅបាន លើកលែងតែយានយន្តមានលេខស៊េរី ។ សេចក្តីអធិប្បាយថា "ទ្រព្យសកម្មទាំងអស់" ឬ "ចលនទ្រព្យទាំងអស់" របស់កូនបំណុលត្រូវចាត់ទុកជាសេចក្តីអធិប្បាយគ្រប់គ្រាន់ លើកលែងតែសេចក្តីអធិប្បាយពីទំនិញប្រើប្រាស់ ។

មាត្រា ៧.-

១-កិច្ចព្រមព្រៀងប្រាតិភោគ ត្រូវតែធ្វើឡើងតាមទម្រង់កំណត់ត្រាជាលាយលក្ខណ៍អក្សរ ។ កិច្ចព្រមព្រៀងប្រាតិភោគ អាចកើតឡើងពីកំណត់ត្រាច្រើនដែលដាក់បញ្ចូលគ្នា ។

២-កិច្ចព្រមព្រៀងប្រាតិភោគ ត្រូវមានប្រសិទ្ធភាពស្របតាមលក្ខខណ្ឌរវាងភាគី និងមានប្រសិទ្ធភាពចំពោះអ្នកទិញទ្រព្យធានានិងម្ចាស់បំណុល លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងក្នុងច្បាប់នេះ ។

៣-កិច្ចព្រមព្រៀងប្រាតិភោគអាចចែងពីសិទ្ធិប្រាតិភោគច្រើនជាងមួយបាន ។

មាត្រា ៨.-

១-ម្ចាស់បំណុលដែលមានកិច្ចធានា ត្រូវយកចិត្តទុកដាក់ក្នុងការឃុំគ្រង និងថែរក្សាទ្រព្យធានាដែលខ្លួនកាន់កាប់ឱ្យបានគង់វង់ ។

២-លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះ បើទ្រព្យធានាស្ថិតក្នុងការកាន់កាប់របស់ម្ចាស់បំណុល :

ក-ចំណាយសមស្របត្រូវចេញដោយកូនបំណុល និងធានាដោយទ្រព្យធានា រាប់បញ្ចូលទាំងថ្លៃធានារ៉ាប់រង ពន្ធអាករនិងថ្លៃចំណាយទាក់ទិននឹងទ្រព្យធានា ។

ខ-ហានិភ័យនៃការបាត់បង់ ឬ ការខូចខាតដោយគ្រោះថ្នាក់ គឺជាបន្ទុករបស់កូនបំណុលចំពោះតែប្រាក់ ដែលលើសពីថ្លៃសំណងធានារ៉ាប់រង ។

គ-ម្ចាស់បំណុលដែលមានកិច្ចធានា អាចរក្សាទុកផលនៃទ្រព្យធានាជាសិទ្ធិប្រាតិភោគបន្ថែម លើកលែងតែផលជារូបិយវត្ថុ ហើយបើមានផលជារូបិយវត្ថុ ត្រូវប្រើដើម្បីទូទាត់កាតព្វកិច្ចប្រាតិភោគ លើកលែងតែផលជារូបិយវត្ថុនោះត្រូវបានផ្ទេរឱ្យទៅកូនបំណុលរួចហើយ ។

មាត្រា ៩.-

១-សិទ្ធិប្រាតិភោគភ្ជាប់ទៅនឹងទ្រព្យធានា ហើយអាចបង្ខំឱ្យកូនបំណុលនិងភាគីទីបីប្រតិបត្តិតាមបានចំពោះទ្រព្យធានា តែក្នុងករណីដែល :

ក-កូនបំណុលបានបញ្ជាក់ការឯកភាព លើកិច្ចព្រមព្រៀងប្រាតិភោគដែល

ចែងពីទ្រព្យធានា

ខ-ម្ចាស់បំណុលបានផ្តល់តម្លៃឱ្យទៅកូនបំណុល

គ-កូនបំណុលមានសិទ្ធិលើទ្រព្យធានា ឬអំណាចផ្ទេរសិទ្ធិលើទ្រព្យធានាឱ្យទៅម្ចាស់បំណុលដែលមានកិច្ចធានា ។

២-លើកលែងតែភាគីបានព្រមព្រៀងផ្សេងពីនេះ ការភ្ជាប់សិទ្ធិប្រាតិភោគទៅនឹងទ្រព្យធានាផ្តល់ឱ្យម្ចាស់បំណុល មានកិច្ចធានានូវសិទ្ធិលើផលនៃទ្រព្យធានាដូចមានចែងក្នុងច្បាប់នេះ ។

## ជំពូកទី ២
## សុក្រឹតកម្ម និង អាទិភាព

**មាត្រា ១០.-**

១-សិទ្ធិប្រាតិភោគមានសុក្រឹតភាព កាលណាសិទ្ធិប្រាតិភោគនេះបានភ្ជាប់ទៅនឹងទ្រព្យធានា និងបានបំពេញតាមលក្ខខណ្ឌទាំងអស់នៃមាត្រានេះ ។

២-ដើម្បីឱ្យសិទ្ធិប្រាតិភោគមានសុក្រឹតភាព ត្រូវតែតម្កល់លិខិតជូនដំណឹងតាមច្បាប់នេះ លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងក្នុងច្បាប់នេះ ។

៣-សិទ្ធិប្រាតិភោគលើប្រាក់ខ្ចីទិញទំនិញប្រើប្រាស់ មានសុក្រឹតភាពនៅពេលដែលសិទ្ធិប្រាតិភោគភ្ជាប់នឹងទំនិញនោះ ហើយមិនចាំបាច់តម្កល់លិខិតជូនដំណឹងដើម្បីធ្វើសុក្រឹត-កម្មឡើយ ។

៤-សិទ្ធិប្រាតិភោគលើទំនិញ លិខិតស្នាម ឯកសារ ឬ កិច្ចសន្យាលក់ដែលមានកិច្ចធានាអាចមានសុក្រឹតភាព ដោយការតម្កល់លិខិតជូនដំណឹង ឬ ដោយម្ចាស់បំណុលមានកិច្ចធានាកាន់កាប់ទ្រព្យធានា ។

៥-សិទ្ធិប្រាតិភោគបន្តមានសុក្រឹតភាពដោយការកាន់កាប់ គិតចាប់ពីពេលកាន់កាប់ ហើយសុក្រឹតភាពនេះ ត្រូវបន្តអនុភាពតែក្នុងពេលមានការកាន់កាប់ប៉ុណ្ណោះ ។

៦-សិទ្ធិប្រាតិភោគលើរូបិយវត្ថុ អាចមានសុក្រឹតភាពតែក្នុងករណីដែលម្ចាស់បំណុលមានកិច្ចធានាបានកាន់កាប់រូបិយវត្ថុ លើកលែងតែផលទ្រព្យធានាដែលជារូបិយវត្ថុ ។

៧-សិទ្ធិប្រាតិភោគលើយានយន្តមានលេខស៊េរី អាចត្រូវធ្វើសុក្រឹតកម្មដោយការតម្កល់លិខិតជូនដំណឹងដែលពណ៌នាជាទូទៅ ឬ បញ្ជាក់ពីលេខស៊េរីនៃយានយន្តនោះ ។

៨-សិទ្ធិប្រាតិភោគក្រៅពីសិទ្ធិប្រាតិភោគលើរូបិយវត្ថុ អាចត្រូវធ្វើសុក្រឹតកម្មមុន ឬ ក្នុងពេល ឬ បន្ទាប់ពីរយៈពេលដែលម្ចាស់បំណុលដែលមានកិច្ចធានា បានកាន់កាប់ទ្រព្យធានា ។

៩-មិនចាំបាច់តម្កល់លិខិតជូនដំណឹង ដើម្បីធ្វើសុក្រឹត្យកម្មសិទ្ធិប្រាតិភោគលើផលនៃទ្រព្យធានាឡើយ ។

១០-កាលណាទំនិញស្ថិតក្នុងការកាន់កាប់របស់អ្នកទទួលបញ្ញើ ដែលបានចេញឯកសារបញ្ជាក់ពីទំនិញនេះ សិទ្ធិប្រាតិភោគលើទំនិញអាចមានសុក្រឹតភាព ដោយការធ្វើសុក្រឹតកម្មសិទ្ធិប្រាតិភោគលើឯកសារនោះ ។ សិទ្ធិប្រាតិភោគដែលត្រូវបានធ្វើសុក្រឹតកម្មតាមមធ្យោបាយផ្សេង ក្នុងអំឡុងពេលដែលអ្នកទទួលបញ្ញើកាន់កាប់ទំនិញ ត្រូវមានអាទិភាពក្នុងលំដាប់ បន្ទាប់ពីសិទ្ធិប្រាតិភោគដែលត្រូវធ្វើសុក្រឹតកម្មលើឯកសារ ។

១១-ការធ្វើសុក្រឹតកម្មសិទ្ធិប្រាតិភោគលើទ្រព្យធានា នាំឱ្យសិទ្ធិប្រាតិភោគលើកិច្ចធានាដែលគាំទ្រទ្រព្យធានានេះត្រូវមានសុក្រឹតភាពផងដែរ ។ ភាគីមិនចាំបាច់តម្កល់លិខិតជូនដំណឹង ដើម្បីធ្វើសុក្រឹត្យកម្មសិទ្ធិប្រាតិភោគលើកិច្ចធានានេះឡើយ ។

១២-ការធ្វើសុក្រឹតកម្មសិទ្ធិប្រាតិភោគលើសិទ្ធិទទួលប្រាក់ ឬ ការបំពេញកាតព្វកិច្ចនាំឱ្យសិទ្ធិប្រាតិភោគលើកិច្ចសន្យាអ៊ីប៉ូតែកស្តីពីអចលនទ្រព្យ ដែលធានាសិទ្ធិទទួលប្រាក់នោះមានសុក្រឹតភាពផងដែរ ។

**មាត្រា ១១.-**

១-សិទ្ធិប្រាតិភោគត្រូវមានសុក្រឹតភាពជាបន្ត បើដំបូងត្រូវធ្វើសុក្រឹតកម្មតាមរបៀបមួយ ហើយក្រោយមកមានសុក្រឹតភាពតាមរបៀបផ្សេង បើគ្មានចន្លោះរយៈពេលដែលគ្មានសុក្រឹតភាពរវាងចំណុចទាំងពីរនេះទេ ។

២-ក្នុងករណីដែលម្ចាស់បំណុលដែលមានកិច្ចធានា ផ្ទេរសិទ្ធិប្រាតិភោគដែលមានសុក្រឹតភាព មិនចាំបាច់តម្កល់លិខិតជូនដំណឹងតាមច្បាប់នេះ ដើម្បីបន្តសុក្រឹតភាពសិទ្ធិ-

ប្រាតិភោគចំពោះម្ចាស់បំណុលរបស់កូនបំណុល និងបុគ្គលដែលទទួលទ្រព្យធានាពីកូនបំណុលឡើយ ។

**មាត្រា ១២.-**

១-សិទ្ធិប្រាតិភោគច្រើនលើទ្រព្យធានាតែមួយ ត្រូវមានអាទិភាពអនុលោមតាមពេលនៃការតម្កល់ ឬ ការធ្វើសុក្រឹតកម្ម លើកលែងតែច្បាប់នេះចែងផ្សេងពីនេះ ។

២-អាទិភាពត្រូវគិតចាប់ពីកាលបរិច្ឆេទនៃការតម្កល់លិខិតជូនដំណឹងពីទ្រព្យធានា ឬ ពីពេលដែលសិទ្ធិប្រាតិភោគមានសុក្រឹតភាព គឺយកកាលបរិច្ឆេទណាមួយ ដែលកើតឡើងមុន បើគ្មានចន្លោះរយៈពេលដែលគ្មានការតម្កល់និងគ្មានសុក្រឹតភាពក្រោយពីនេះទេ ។

៣-សិទ្ធិប្រាតិភោគដែលត្រូវភ្ជាប់នឹងទ្រព្យធានាមុនគេ ត្រូវមានអាទិភាពលើសិទ្ធិ-ប្រាតិភោគផ្សេងទៀត ដែលមិនបានតម្កល់ ឬមិនបានធ្វើសុក្រឹត្យកម្ម ។

៤-កាលបរិច្ឆេទនៃការតម្កល់ ឬសុក្រឹតកម្មសម្រាប់ទ្រព្យធានា ត្រូវចាត់ទុកជាកាល-បរិច្ឆេទនៃការតម្កល់ ឬ សុក្រឹតកម្មសម្រាប់ផលនៃទ្រព្យធានានេះផងដែរ ។

**មាត្រា ១៣.-**

សិទ្ធិប្រាតិភោគមានអាទិភាពលើសិទ្ធិរបស់គាហកនៃសិទ្ធិឃាត់ទុក លើកលែងតែគាហកនៃសិទ្ធិឃាត់ទុកបានតម្កល់លិខិតជូនដំណឹងពីសិទ្ធិរបស់ខ្លួនតាមច្បាប់នេះ :

១-មុនពេលសិទ្ធិប្រាតិភោគមានសុក្រឹត្យភាព

២-មុនពេលម្ចាស់បំណុលតម្កល់លិខិតជូនដំណឹងពីទ្រព្យធានា ។

**មាត្រា ១៤.-**

១-បុគ្គលត្រូវទទួលទ្រព្យធានាដោយគ្មានជាប់សិទ្ធិប្រាតិភោគ បើបុគ្គលបានទិញនិងផ្តល់តម្លៃដោយមិនបានដឹងថាមានសិទ្ធិប្រាតិភោគ និងមុនពេលដែលសិទ្ធិប្រាតិភោគមានសុក្រឹតភាព ។ ក្នុងករណីទ្រព្យធានាជាទ្រព្យរូបី បុគ្គលនឹងទទួលបានទ្រព្យធានាដោយគ្មានជាប់សិទ្ធិប្រាតិភោគ បើបុគ្គលបានទិញផ្តល់តម្លៃ និងទទួលទ្រព្យធានាដោយមិនបានដឹងថាមានសិទ្ធិប្រាតិភោគ និងមុនពេលដែលសិទ្ធិប្រាតិភោគមានសុក្រឹតភាព ។

ROYAUME DU CAMBODGE · MINISTÈRE DU PALAIS ROYAL

២-ថ្វីបើមានចែងក្នុងចំណុចទី ១ ក្តី អ្នកទិញក្នុងអាជីវកម្មធម្មតាត្រូវទទួលកម្មសិទ្ធិដោយគ្មានជាប់សិទ្ធិប្រាតិភោគលើទំនិញឡើយ ទោះបីសិទ្ធិប្រាតិភោគមានសុក្រឹតភាពក៏ដោយ និងទោះបីជាអ្នកទិញបានដឹងថា មានជាប់សិទ្ធិប្រាតិភោគក៏ដោយ ។

៣-ថ្វីបើមានចែងក្នុងចំណុចទី ១ ក្តី អ្នកទិញទំនិញប្រើប្រាស់នឹងទទួលបានកម្មសិទ្ធិដោយគ្មានជាប់សិទ្ធិប្រាតិភោគលើទំនិញ ទោះបីសិទ្ធិប្រាតិភោគមាន ឬ គ្មានសុក្រឹតភាពក៏ដោយ បើអ្នកទិញបានទិញដោយមិនដឹងថាមានសិទ្ធិប្រាតិភោគ និងមុនពេលមានការតម្កល់លិខិតជូនដំណឹងពីទំនិញប្រើប្រាស់នេះ ។

៤-ថ្វីបើមានចែងក្នុងចំណុចទី ១ ក្តី អ្នកទិញយានយន្តមានលេខស៊េរី ត្រូវទទួលយានយន្តមានលេខស៊េរី ដោយគ្មានជាប់សិទ្ធិប្រាតិភោគ តែក្នុងករណីដែលអ្នកទិញបានទិញដោយមិនបានដឹងថាមានសិទ្ធិប្រាតិភោគ ហើយលិខិតជូនដំណឹងដែលតម្កល់មិនបានពណ៌នាពីយានយន្តមានលេខស៊េរីនេះ ឬ លិខិតជូនដំណឹងដែលតម្កល់នោះបានចុះលេខស៊េរីមិនត្រឹមត្រូវ ។

៥-ថ្វីបើមានចែងក្នុងចំណុចទី ១ ក្តី អ្នកទិញកសិផលត្រូវទទួលបាន :

ក-កសិផលដោយគ្មានជាប់សិទ្ធិប្រាតិភោគ បើអ្នកទិញយកកសិផលទៅប្រើជាទំនិញប្រើប្រាស់ ។

ខ-កសិផលដោយគ្មានជាប់សិទ្ធិប្រាតិភោគ បើអ្នកទិញយកកសិផលទៅប្រើក្នុងគោលបំណងក្រៅពីទំនិញប្រើប្រាស់ ហើយអ្នកទិញបានផ្តល់តម្លៃ និងបានទទួលកសិផលដោយមិនបានដឹងថាមានសិទ្ធិប្រាតិភោគ និងមុនពេលសិទ្ធិប្រាតិភោគមានសុក្រឹតភាព ។

៦-អ្នកទទួលប្រាក់ផ្ទេរត្រូវទទួលប្រាក់ដោយគ្មានជាប់សិទ្ធិប្រាតិភោគ លើកលែងតែអ្នកទទួលបានសុំគ្រលំជាមួយកូនបំណុលដោយបំពានលើសិទ្ធិរបស់ម្ចាស់បំណុលដែលមានកិច្ចធានា ។

៧-អ្នកទទួលផលនៃទ្រព្យធានាដែលជាមូលនិធិក្នុងគណនីប្រាក់បញ្ញើ គណនីមូលបត្រឡានទ្រព្យ គណនីសញ្ច័យ សៀវភៅធនាគារ ឬ គណនីសាច់ប្រាក់ដទៃទៀត ត្រូវទទួលបានមូលនិធិដោយគ្មានជាប់សិទ្ធិប្រាតិភោគ លើកលែងតែអ្នកទទួលបានសុំគ្រលំជាមួយកូនបំណុលដោយបំពានលើសិទ្ធិរបស់ម្ចាស់បំណុលដែលមានកិច្ចធានា ។

៉

មាត្រា ១៥.-

១-អ្នកជួលទ្រព្យធានាត្រូវទទួលបានសិទ្ធិ ដោយគ្មានជាប់សិទ្ធិប្រាតិភោគ បើអ្នកជួលបានទទួលទំនិញ ដោយមិនបានដឹងថាមានសិទ្ធិប្រាតិភោគ និងមុនពេលដែលសិទ្ធិប្រាតិភោគមានសុក្រឹតភាព ។

២-ថ្វីបើមានចែងក្នុងចំណុចទី ១ ក្តី អ្នកជួលទំនិញក្នុងអាជីវកម្មធម្មតាត្រូវទទួលបានសិទ្ធិដោយគ្មានជាប់សិទ្ធិប្រាតិភោគលើទំនិញ ទោះបីសិទ្ធិប្រាតិភោគមានសុក្រឹតភាព និងទោះបីជាអ្នកជួលបានដឹងថាមានសិទ្ធិប្រាតិភោគក៏ដោយ ។

៣-ថ្វីបើមានចែងក្នុងចំណុចទី ១ ក្តី អ្នកជួលត្រូវទទួលបានយានយន្តមានលេខស៊េរីដោយគ្មានជាប់សិទ្ធិប្រាតិភោគ តែក្នុងករណីដែលអ្នកជួលបានជួលដោយមិនបានដឹងថាមានសិទ្ធិប្រាតិភោគ ហើយលិខិតជូនដំណឹងដែលតម្កល់មិនបានពណ៌នាត្រឹមត្រូវពីយានយន្តមានលេខស៊េរីនេះ ។

មាត្រា ១៦.-

បើបុគ្គលតម្កល់លិខិតជូនដំណឹងពីសិទ្ធិប្រាតិភោគលើប្រាក់ខ្ចីទិញមុនពេល ឬ ក្នុងអំឡុងពេលប្រាំ(០៥)ថ្ងៃ បន្ទាប់ពីកូនបំណុលបានទទួលទំនិញ សិទ្ធិប្រាតិភោគនេះមានអាទិភាពលើសិទ្ធិរបស់អ្នកទិញ អ្នកជួល ឬគាហកនៃសិទ្ធិឃាត់ទុកដែលកើតឡើងក្នុងចន្លោះពេលដែលសិទ្ធិប្រាតិភោគភ្ជាប់នឹងទំនិញ និងពេលនៃការតម្កល់លិខិតជូនដំណឹង ។

មាត្រា ១៧.-

១-សិទ្ធិប្រាតិភោគត្រូវបន្តភ្ជាប់នឹងទ្រព្យធានា ថ្វីបើមានការលក់ ការជួល ការផ្តល់អាជ្ញាប័ណ្ណ ការប្តូរ ឬការជម្រះចោលទ្រព្យធានាក្តី លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងក្នុងច្បាប់នេះ ឬភាគីបានព្រមព្រៀងផ្សេងពីនេះ ។

២-នៅពេលជម្រះចោលទ្រព្យធានា សិទ្ធិប្រាតិភោគត្រូវបន្តភ្ជាប់នឹងផលនៃទ្រព្យធានា លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងក្នុងច្បាប់នេះ ឬភាគីបានព្រមព្រៀងផ្សេងនេះ ។

៣-សិទ្ធិប្រាតិភោគលើផលនៃទ្រព្យធានា គឺជាសិទ្ធិប្រាតិភោគមានសុក្រឹតភាពជាបន្តក្នុងករណីដែលសិទ្ធិប្រាតិភោគលើទ្រព្យធានាដើម ត្រូវបានធ្វើសុក្រឹតកម្ម ប៉ុន្តែសិទ្ធិនេះក្លាយ

ទៅជាគ្មានសុក្រឹតភាពក្នុងរយៈពេលម្ភៃ(២០)ថ្ងៃ បន្ទាប់ពីកូនបំណុលទទួលផលនៃទ្រព្យធានានេះ លើកលែងតែ ៖

- បានតម្កល់លិខិតជូនដំណឹងសម្រាប់ទ្រព្យធានាដើម ហើយផលនៃទ្រព្យធានាជារូបិយវត្ថុ ឬផលនៃទ្រព្យធានាមានលក្ខណៈដូចបញ្ជាក់ក្នុងលិខិតជូនដំណឹង ឬ

- សិទ្ធិប្រាតិភោគលើផលនៃទ្រព្យធានា ត្រូវបានធ្វើសុក្រឹតកម្មមុនផុតរយៈពេលម្ភៃ (២០)ថ្ងៃ ។

មាត្រា ១៨.-

១-សិទ្ធិប្រាតិភោគលើប្រាក់ខ្ចីទិញឧបករណ៍ ដែលមានសុក្រឹតភាពត្រូវមានអាទិភាពលើសិទ្ធិប្រាតិភោគឯទៀតលើឧបករណ៍តែមួយ និងមានអាទិភាពលើផលនៃឧបករណ៍ផងដែរ បើសិទ្ធិប្រាតិភោគលើប្រាក់ខ្ចីទិញត្រូវបានធ្វើសុក្រឹតកម្មនៅពេលដែលកូនបំណុលបានកាន់កាប់ឧបករណ៍ ឬក្នុងរយៈពេលប្រាំ(០៥)ថ្ងៃ បន្ទាប់ពីការកាន់កាប់ ។

២-សិទ្ធិប្រាតិភោគលើប្រាក់ខ្ចីទិញសារពើភណ្ឌ ឬសត្វចិញ្ចឹមគ្រប់ប្រភេទ ត្រូវមានអាទិភាពលើសិទ្ធិប្រាតិភោគផ្សេងទៀតលើសារពើភណ្ឌ ឬសត្វចិញ្ចឹមប្រភេទតែមួយ ប្រសិនបើ ៖

ក-សិទ្ធិប្រាតិភោគលើប្រាក់ខ្ចីទិញ ត្រូវបានធ្វើសុក្រឹតកម្មនៅពេលដែលកូនបំណុលបានកាន់កាប់សារពើភណ្ឌ ឬសត្វចិញ្ចឹមគ្រប់ប្រភេទ និង

ខ-ម្ចាស់បំណុលដែលមានកិច្ចធានាពីប្រាក់ខ្ចីទិញ ជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អ្នកកាន់កាប់សិទ្ធិប្រាតិភោគផ្សេងទៀត បើអ្នកកាន់កាប់នោះបានតម្កល់លិខិតជូនដំណឹងសម្រាប់សារពើភណ្ឌ ឬ សត្វចិញ្ចឹមប្រភេទដូចគ្នា មុនពេលដែលម្ចាស់បំណុលមានកិច្ចធានាពីប្រាក់ខ្ចីទិញបានតម្កល់លិខិតជូនដំណឹង ។ លិខិតជូនដំណឹងត្រូវតែអធិប្បាយអំពីសារពើភណ្ឌ ឬសត្វចិញ្ចឹមគ្រប់ប្រភេទ និងបញ្ជាក់ថាបុគ្គលដែលផ្តល់លិខិតជូនដំណឹងបានទទួល ឬនឹងបានទទួលសិទ្ធិប្រាតិភោគលើប្រាក់ខ្ចីទិញសារពើភណ្ឌ ឬ សត្វចិញ្ចឹមរបស់កូន

សំណៅ

មាត្រា ១៩.-

សិទ្ធិឃាត់ទុកទំនិញដែលបង្កើតឡើងដោយច្បាប់ត្រូវមានអាទិភាពលើសិទ្ធិប្រាតិភោគដែលមានសុក្រឹតភាព ប្រសិនបើ :

១-សិទ្ធិឃាត់ទុកត្រូវបង្កើតជាផលប្រយោជន៍របស់បុគ្គល ដែលកាន់កាប់ទំនិញសម្រាប់ធានាការទូទាត់ថ្លៃសម្ភារៈ ឬសេវាកម្មដែលទាក់ទិននឹងទំនិញ និង

២-សម្ភារៈ ឬសេវាកម្មនោះត្រូវបានផ្តល់ក្នុងដំណើរការអាជីវកម្មធម្មតា ។

មាត្រា ២០.-

១-សិទ្ធិប្រាតិភោគអាចបង្កើតលើទំនិញដែលជាចលនវត្ថុតាំងភ្ជាប់ ហើយអាចបន្តភ្ជាប់នឹងទំនិញដែលក្លាយទៅជាចលនវត្ថុតាំងភ្ជាប់ ។

២-សិទ្ធិប្រាតិភោគ លើសម្ភារៈសំណង់ធម្មតាត្រូវបញ្ចប់នៅពេលសម្ភារៈនោះត្រូវបានបញ្ចូលទៅក្នុងអចលនវត្ថុ ។

៣-ម៉ាស៊ីននៃរោងចក្រ ម៉ាស៊ីនប្រើក្នុងការិយាល័យដែលអាចរុះរើបានដោយងាយស្រួល បរិក្ខារក្នុងផ្ទះ ឬវត្ថុដទៃទៀត ដែលអាចយកទៅប្រើដាច់ដោយឡែកពីដី និងអាគារបាន មិនចាត់ទុកជាចលនវត្ថុតាំងភ្ជាប់ឡើយ ។ អាទិភាពលើចលនវត្ថុទាំងនេះមិនត្រូវកំណត់តាមមាត្រានេះទេ ហើយមិនរងឥទ្ធិពលពីសិទ្ធិរបស់ម្ចាស់អចលវត្ថុ ឬម្ចាស់បំណុលអ៊ីប៉ូតែកលើដីឡើយ ។

៤-សិទ្ធិប្រាតិភោគលើចលនវត្ថុតាំងភ្ជាប់ ត្រូវមានអាទិភាពបន្ទាប់ពីសិទ្ធិប្រត្យ័ក្សលើអចលនវត្ថុ លើកលែងតែសិទ្ធិដែលមានចែងក្នុងច្បាប់នេះ ។

៥-សិទ្ធិប្រាតិភោគលើចលនវត្ថុតាំងភ្ជាប់ដែលមានសុក្រឹតភាព មានអាទិភាពលើសិទ្ធិរបស់ម្ចាស់អចលនវត្ថុ គាហកនៃសិទ្ធិឃាត់ទុក ឬ ម្ចាស់បំណុលអ៊ីប៉ូតែក ទោះបីជាខបញ្ញត្តិនៃកិច្ចសន្យាអ៊ីប៉ូតែកចែងផ្សេងពីនេះក្តី ប្រសិនបើ :

ក-លិខិតជូនដំណឹង ត្រូវបានតម្កល់មុនការតម្កល់លិខិតជូនដំណឹងពីសិទ្ធិរបស់គាហកនៃសិទ្ធិឃាត់ទុកដែលច្បាប់នេះតម្រូវ ឬមុនពេលចុះបញ្ជីកិច្ចសន្យាអ៊ីប៉ូតែក ឬមុនពេលចុះបញ្ជីសិទ្ធិរបស់ម្ចាស់អចលនវត្ថុ នៅការិយាល័យចុះបញ្ជីអចលនវត្ថុដែលមានសមត្ថកិច្ច

ខ-សិទ្ធិប្រាតិភោគជាសិទ្ធិប្រាតិភោគលើប្រាក់ខ្ចីទិញ ដែលកូនបំណុលបានផ្តល់មុនពេលទំនិញក្លាយទៅជាចលនវត្ថុតាំងភ្ជាប់ ហើយលិខិតជូនដំណឹងត្រូវបានតម្កល់មុនពេលទំនិញក្លាយទៅជាចលវត្ថុតាំងភ្ជាប់ ឬប្រាំ(១៥)ថ្ងៃ បន្ទាប់ពីទំនិញនេះក្លាយទៅជាចលនវត្ថុតាំងភ្ជាប់ ។

អាទិភាពដែលបង្កើតក្នុងចំណុច ខ នៃវាក្យខណ្ឌនេះ មិនមានប្រសិទ្ធភាពលើអ៊ីប៉ូតែកធានាការសាងសង់ឡើយ ។ ត្រូវចាត់ទុកជាអ៊ីប៉ូតែកធានាការសាងសង់ រាល់អ៊ីប៉ូតែកដែលធានាកាតព្វកិច្ចបង់ប្រាក់ថ្លៃសាងសង់ ដើម្បីកែលំអលើអចលនទ្រព្យ ហើយអចលនទ្រព្យដែលបានដាក់អ៊ីប៉ូតែកធានាកាតព្វកិច្ចនេះ ត្រូវបានចុះបញ្ជីតាមច្បាប់ភូមិបាលជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

៦- ម្ចាស់បំណុលមានកិច្ចធានា ដែលមានអាទិភាពតាមមាត្រានេះ អាចដក ឬរុះរើយកចលនវត្ថុតាំងភ្ជាប់វិញនៅពេលកូនបំណុលមិនសងបំណុល ។

ក-ម្ចាស់បំណុលដែលមានកិច្ចធានាដែលដក ឬរុះរើយកចលនវត្ថុតាំងភ្ជាប់ត្រូវតែចេញថ្លៃជួសជុលការខូចខាតលើអចលនទ្រព្យភ្លាមៗ ឱ្យទៅម្ចាស់បំណុលអ៊ីប៉ូតែកដែលមិនមែនជាកូនបំណុល ។

ខ-ម្ចាស់បំណុលដែលមានកិច្ចធានា មិនចាំបាច់ចេញសំណងជូនម្ចាស់បំណុលអ៊ីប៉ូតែក ឬ កម្មសិទ្ធិករចំពោះការចុះតម្លៃដោយសារគ្មានទំនិញដែលបានយកចេញ ឬដោយភាពចាំបាច់នៃការដាក់ជំនួសវិញឡើយ ។

គ-បុគ្គលដែលមានសិទ្ធិទារសំណងនេះអាចបដិសេធការយកចេញ ឬការរុះរើ រហូតទាល់តែម្ចាស់បំណុល ដែលមានកិច្ចធានាផ្តល់ការធានាគ្រប់គ្រាន់ក្នុងការបំពេញកាតព្វកិច្ចចេញសំណងនេះ ។

## មាត្រា ២១.-

សិទ្ធិប្រាតិភោគលើផលដំណាំដែលដាំដុះលើអចលនទ្រព្យ មានអាទិភាពលើសិទ្ធិរបស់កម្មសិទ្ធិករ ឬ ម្ចាស់បំណុលអ៊ីប៉ូតែក បើកូនបំណុលបានកាន់កាប់អចលនទ្រព្យ ឬមានសិទ្ធិលើអចលនទ្រព្យ ដែលបានចុះបញ្ជីតាមច្បាប់ភូមិបាលជាធរមាននៃព្រះរាជាណាចក្រ

**មាត្រា ២២.-**

១-សិទ្ធិប្រាតិភោគអាចបង្កើតលើវត្ថុចំណុះ ហើយសិទ្ធិប្រាតិភោគនេះបន្តអានុភាពលើទ្រព្យធានាដែលក្លាយទៅជាវត្ថុចំណុះ ។ បើសិទ្ធិប្រាតិភោគត្រូវធ្វើសុក្រឹតកម្មនៅពេលដែលទ្រព្យធានាក្លាយទៅជាវត្ថុចំណុះសិទ្ធិប្រាតិភោគត្រូវបន្តសុក្រឹតភាពលើវត្ថុចំណុះនោះ ។

២-នៅពេលកូនបំណុលមិនសងបំណុល ម្ចាស់បំណុលដែលមានកិច្ចធានាអាចដកយកវត្ថុចំណុះនោះចេញពីចលនវត្ថុផ្សេងនោះបាន បើសិទ្ធិប្រាតិភោគលើវត្ថុចំណុះមានអាទិភាពលើការទាមទាររបស់បុគ្គលផ្សេងទៀត ដែលមានសិទ្ធិលើចលនវត្ថុទាំងមូល ។

៣-ភាគីដែលដកយកវត្ថុចំណុះត្រូវសងថ្លៃចំណាយជួសជុល ឬ ការខូចខាតជាក់ស្តែងលើចលនវត្ថុទាំងមូលឱ្យទៅអ្នកកាន់កាប់ដែលមិនមែនជាកូនបំណុលនូវផលប្រយោជន៍លើចលនវត្ថុទាំងមូល ឬចលនវត្ថុផ្សេងនោះ ដែលសិទ្ធិនៃអ្នកកាន់កាប់នេះមានអាទិភាពលើសិទ្ធិរបស់ម្ចាស់បំណុលដែលមានកិច្ចធានា ហើយ :

ក-ម្ចាស់បំណុលដែលមានកិច្ចធានា មិនចាំបាច់ចេញសងការចុះតម្លៃចលនវត្ថុទាំងមូលដែលបណ្តាលឡើងដោយសារគ្មានវត្ថុចំណុះ ឬភាពចាំបាច់នៃការដាក់ជំនួសវិញឡើយ ។

ខ-បុគ្គលដែលមានសិទ្ធិទារសំណងនេះ អាចបដិសេធមិនអនុញ្ញាតឱ្យរុះរើយកវត្ថុចំណុះ លុះត្រាតែម្ចាស់បំណុលដែលមានកិច្ចធានាផ្តល់ការធានាច្បាស់ពីការបំពេញកាតព្វកិច្ចចេញសំណងនេះ ។

**មាត្រា ២៣.-**

១-សិទ្ធិប្រាតិភោគមិនអាចបង្កើតលើទំនិញនីមួយៗ ដែលលាយបញ្ចូលគ្នាឡើយ ។

២-ប្រសិនបើទ្រព្យធានាក្លាយទៅជាទំនិញបញ្ចូលគ្នា សិទ្ធិប្រាតិភោគត្រូវភ្ជាប់នឹងផលិតផល ឬ សមាសធាតុរួម ។

៣-បើសិទ្ធិប្រាតិភោគមានសុក្រឹតភាព មុនពេលទ្រព្យធានាក្លាយទៅជាទំនិញបញ្ចូលគ្នា សិទ្ធិប្រាតិភោគដែលភ្ជាប់ទៅនឹងផលិតផល ឬសមាសធាតុរួមត្រូវមានសុក្រឹតភាពដោយមិនចាំបាច់ផ្តល់លិខិតជូនដំណឹងឡើយ ។ អាទិភាពនៃសិទ្ធិប្រាតិភោគលើផលិតផល ឬ

សមាសធាតុរួម ត្រូវគិតចាប់ពីពេលធ្វើសុក្រឹតកម្មសិទ្ធិប្រាតិភោគលើទ្រព្យធានាដែលបាន ក្លាយទៅជាទំនិញបញ្ចូលគ្នា ។

៤- ក្នុងករណីមានសិទ្ធិប្រាតិភោគលើសពីមួយភ្ជាប់ទៅនឹងផលិតផល ឬសមាសធាតុរួម អាទិភាពត្រូវកំណត់តាមវិធានខាងក្រោមនេះ :

ក- សិទ្ធិប្រាតិភោគដែលមានសុក្រឹតភាព ត្រូវមានអាទិភាពលើសិទ្ធិប្រាតិភោគដែលគ្មានសុក្រឹតភាពក្នុងពេលដែលទ្រព្យធានាក្លាយទៅជាទំនិញបញ្ចូលគ្នា ។

ខ- សិទ្ធិដែលត្រូវភ្ជាប់នឹងផលិតផល ឬសមាសធាតុរួមមុនគេត្រូវមានអាទិភាពលើសិទ្ធិដែលគ្មានសុក្រឹតភាព ។

គ- បើមានសិទ្ធិប្រាតិភោគលើសពីមួយ ត្រូវបានធ្វើសុក្រឹតកម្មសិទ្ធិប្រាតិភោគ ត្រូវមានលំដាប់អាទិភាពស្មើគ្នាតាមសមាមាត្រនៃតម្លៃទ្រព្យធានា នៅពេលទ្រព្យនេះបាន ក្លាយទៅជាទំនិញបញ្ចូលគ្នា ។

## មាត្រា ២៤.-

អ្នកទិញកិច្ចសន្យាលក់ដែលមានកិច្ចធានា ឬ លិខិតស្នាម មានអាទិភាពលើសិទ្ធិប្រាតិភោគផ្សេងលើកិច្ចសន្យាលក់ដែលមានកិច្ចធានា ឬលិខិតស្នាមហើយក៏មានអាទិភាពលើផលនៃកិច្ចសន្យាលក់ ដែលមានកិច្ចធានាឬលិខិតស្នាមផងដែរ ប្រសិនបើ :

-អ្នកទិញបានផ្តល់តម្លៃថ្មីនិងកាន់កាប់កិច្ចសន្យាលក់ដែលមានកិច្ចធានា ឬ លិខិតស្នាមក្នុងដំណើរការអាជីវកម្មធម្មតារបស់ខ្លួន និង

-កិច្ចសន្យាលក់ដែលមានកិច្ចធានា ឬលិខិតស្នាម មិនបានបញ្ជាក់ថាបានផ្ទេរឱ្យទៅភាគីដែលកាន់កាប់សិទ្ធិប្រាតិភោគដែលប្រជែងគ្នា ។

## មាត្រា ២៥.-

១- បុគ្គលអាចធ្វើអនុប្បទានសិទ្ធិរបស់ខ្លួនទាំងអស់ ឬ មួយផ្នែកលើគណនី កិច្ចសន្យាលក់ដែលមានកិច្ចធានា ឬលិខិតស្នាម និងសិទ្ធិលើទ្រព្យអរូបីផ្សេងៗទៀតបាន ។

២- អនុប្បទានសិទ្ធិអាចមានលក្ខណៈជាការធ្វើអនុប្បទានសិទ្ធិទូទៅ ដូចជាសិទ្ធិទទួលប្រាក់នាពេលអនាគត កិច្ចសន្យាលក់ដែលមានកិច្ចធានា លិខិតស្នាម និងទ្រព្យអរូបីដទៃ

៣-អនុប្បទានិកត្រូវគោរពតាមលក្ខខណ្ឌក្នុងកិច្ចព្រមព្រៀងរវាងកូនបំណុលគណនី និងអនុប្បទាយី ។

៤- មិនចាំបាច់ជូនដំណឹងពីការភ្ជាប់សិទ្ធិប្រាតិភោគ សុក្រឹតកម្មសិទ្ធិប្រាតិភោគ ឬការអនុវត្តសិទ្ធិប្រាតិភោគដែលកើតចេញពីអនុប្បទានសិទ្ធិដល់កូនបំណុលគណនីឡើយ ។ ការមិនបានជូនដំណឹងដល់កូនបំណុលគណនី មានអនុភាពចំពោះតែករណីដូចបានចែងក្នុងមាត្រានេះប៉ុណ្ណោះ ។

៥- ក្នុងករណីដែលតម្រូវឱ្យមានការជូនដំណឹងដល់កូនបំណុលគណនី ការផ្តល់ពត៌-មាននោះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ដោយកំណត់ពីសិទ្ធិដែលបានផ្ទេរ ហើយត្រូវមានហត្ថលេខារបស់អនុប្បទាយី ឬអនុប្បទានិក ប៉ុន្តែមិនចាំបាច់រៀបរាប់ពីខ្លឹមសារ ឬលក្ខខណ្ឌនៃអនុប្បទានសិទ្ធិឡើយ ។

៦- កូនបំណុលគណនី ត្រូវបំពេញកាតព្វកិច្ចរបស់ខ្លួន ដោយការបង់ប្រាក់ជូនអនុប្ប-ទាយីរហូតដល់ពេលដែលខ្លួនបានទទួលដំណឹងថាប្រាក់ដែលត្រូវបង់ ឬដល់កាលកំណត់សងត្រូវបានផ្ទេរ ហើយមានការណែនាំឱ្យបង់ជូនអនុប្បទានិក ។

៧-ក្រោយពីបានទទួលការជូនដំណឹងពីអនុប្បទានសិទ្ធិនេះ កូនបំណុលគណនីត្រូវបំពេញកាតព្វកិច្ចរបស់ខ្លួន ដោយបង់ប្រាក់ជូនអនុប្បទានិក ហើយមិនត្រូវបង់ប្រាក់ឱ្យអនុ-ប្បទាយីទៀតទេ ។ ប៉ុន្តែក្នុងករណីមានការស្នើសុំពីកូនបំណុលគណនី អនុប្បទានិកត្រូវផ្តល់ភស្តុតាងគ្រប់គ្រាន់និងទាន់ពេលវេលាថាគណនីនេះត្រូវបានធ្វើអនុប្បទាន ហើយបើអនុ-ប្បទានិកមិនបានធ្វើដូច្នេះទេ កូនបំណុលគណនីអាចបំពេញកាតព្វកិច្ចរបស់ខ្លួនដោយបន្តបង់ប្រាក់ជូនអនុប្បទាយី ទោះបីជាកូនបំណុលគណនីបានទទួលលិខិតជូនដំណឹងពីអនុ-ប្បទានសិទ្ធិនេះក៏ដោយ ។

**មាត្រា ២៦.-**

កិច្ចព្រមព្រៀងរវាងម្ចាស់បំណុលដែលមានកិច្ចធានា និងកូនបំណុលមិនអាចដាក់ឱ្យប្រតិបត្តិតាមបានទេ បើកិច្ចព្រមព្រៀងនេះហាមប្រាម ឬដាក់កំរិតលើការលក់ ឬការផ្ទេរគណនី កិច្ចសន្យាជួល ឬ កិច្ចសន្យាលក់ដែលមានកិច្ចធានា ។

ROYAL CABINET · MINISTÈRE du PALAIS ROYAL

**មាត្រា ២៧.-**

១-កាលណាសិទ្ធិប្រាតិភោគត្រូវបានធ្វើសុក្រឹតកម្មដើម្បីធានាកាតព្វកិច្ច ដោយម្ចាស់បំណុលដែលមានកិច្ចធានា ដើម្បីផ្តល់បុរេប្រទាននាពេលអនាគត សិទ្ធិរបស់គាហកនៃសិទ្ធិឃាត់ទុកមានអាទិភាពលើទ្រព្យធានានេះ ចំពោះតែសិទ្ធិប្រាតិភោគធានាបុរេប្រទានដែលបានផ្តល់បន្ទាប់ពីម្ចាស់បំណុលដែលមានកិច្ចធានាបានដឹងថា មានសិទ្ធិរបស់គាហកនៃសិទ្ធិឃាត់ទុក ឬលើសពីម្ភៃ(២០)ថ្ងៃ បន្ទាប់ពីគាហកនៃសិទ្ធិឃាត់ទុកបានតម្កល់លិខិតជូនដំណឹងពីសិទ្ធិរបស់ខ្លួននៅការិយាល័យតម្កល់លិខិតជូនដំណឹង គឺយកកាលបរិច្ឆេទណាមួយដែលកើតឡើងមុន ។

២-បើលិខិតជូនដំណឹងចែងពីទ្រព្យធានា ដែលកូនបំណុលនឹងមានសិទ្ធិលើទ្រព្យធានាក្នុងពេលអនាគត លិខិតជូនដំណឹងនេះមិនត្រូវមានប្រសិទ្ធភាពលើសិទ្ធិរបស់អភិបាល ឬ អភិបាលបណ្តោះអាសន្ន ដែលតែងតាំងតាមច្បាប់ក្ស័យធនទេ អាទិភាពនេះមានចំពោះតែទ្រព្យធានាដែលបានទទួលក្រោយពេលតម្កល់លិខិតជូនដំណឹង នៅការិយាល័យតម្កល់តាមបទប្បញ្ញត្តិច្បាប់ស្តីពីក្ស័យធន ។

**មាត្រា ២៨.-**

បុគ្គលដែលមានអាទិភាពតាមច្បាប់នេះ អាចយល់ព្រមកែប្រែ ឬលុបចោលអាទិភាពនេះបាន ។ ភាគីមិនចាំបាច់តម្កល់លិខិតជូនដំណឹងពីការព្រមព្រៀងកែប្រែ ឬ លុបចោលអាទិភាពនេះឡើយ ។

## ជំពូកទី ៣
## ការតម្កល់លិខិតជូនដំណឹង

**មាត្រា ២៩.-**

ការិយាល័យតម្កល់លិខិតជូនដំណឹងនៃប្រតិបត្តិការ ដែលមានកិច្ចធានាត្រូវបង្កើតនៅក្រសួងពាណិជ្ជកម្ម ។

មាត្រា ៣០.-

ការិយាល័យនេះជាទីកន្លែងដែលត្រូវតម្កល់ :

១-លិខិតជូនដំណឹងដើម្បីធ្វើសុក្រឹតកម្មសិទ្ធិប្រាតិភោគលើទ្រព្យធានាដែលចែងក្នុងច្បាប់នេះ លើកលែងតែទ្រព្យធានាដូចបានកំណត់ក្នុងមាត្រា ៤៤ នៃច្បាប់នេះនិង

២-លិខិតជូនដំណឹងពីសិទ្ធិរបស់គាហកនៃសិទ្ធិឃាត់ទុក ។

មាត្រា ៣១.-

១-ក្រសួងពាណិជ្ជកម្ម មានអំណាចចេញលិខិតបទដ្ឋានទាំងឡាយដែលមានចែងក្នុងច្បាប់នេះ ។

២-លិខិតបទដ្ឋានរបស់ក្រសួងពាណិជ្ជកម្ម មិនត្រូវផ្ទុយពីបទប្បញ្ញត្តិនៃច្បាប់នេះ ឬគោលបំណងលើកស្ទួយសកម្មភាពពាណិជ្ជកម្មដែលចែងក្នុងច្បាប់នេះឡើយ ។

៣-លិខិតបទដ្ឋានអាចចែងពីវិធីបង់ថ្លៃសេវាកម្ម ដែលកំណត់ដោយច្បាប់នេះ ។

៤-ក្រសួងពាណិជ្ជកម្មត្រូវអនុញ្ញាតឱ្យមានការតម្កល់លិខិតជូនដំណឹង និងការស្រាវជ្រាវរកកំណត់ត្រាតាមមធ្យោបាយអេឡិចត្រូនិក ។ ប៉ុន្តែក្រសួងពាណិជ្ជកម្មអាចចេញលិខិតបទដ្ឋានសម្រាប់អនុញ្ញាតឱ្យដាក់ជូនលិខិតជូនដំណឹង និងការស្នើសុំស្រាវជ្រាវរកកំណត់ត្រាតាមមធ្យោបាយផ្សេងពីនេះ ដែលអាចបំប្លែងទៅជាកំណត់ត្រាអេឡិចត្រូនិកបាន ។ កំណត់ត្រាអេឡិចត្រូនិករបស់ការិយាល័យតម្កល់ ត្រូវចាត់ទុកជាកំណត់ត្រាផ្លូវការនៃការតម្កល់ ។

៥-បើក្រសួងពាណិជ្ជកម្មចេញលិខិតបទដ្ឋានសម្រាប់អនុញ្ញាតការដាក់ជូនលិខិតជូនដំណឹងនិងការស្នើសុំស្រាវជ្រាវរកកំណត់ត្រា តាមមធ្យោបាយផ្សេងពីមធ្យោបាយអេឡិចត្រូនិក ក្រសួងពាណិជ្ជកម្មអាចកំណត់នូវទម្រង់បែបបទសម្រាប់ដាក់ជូនលិខិតជូនដំណឹងនិងការស្នើសុំស្រាវជ្រាវរកកំណត់ត្រា ។

មាត្រា ៣២.-

១-ព័ត៌មានដែលចែងក្នុងលិខិតជូនដំណឹង ដែលតម្កល់តាមច្បាប់នេះជាកំណត់ត្រាសាធារណៈ ។

ROYAUME DU CAMBODGE
LE MINISTRE du PALAIS ROYAL

២-ឧបសម្ព័ន្ធ និងកំណត់ត្រាផ្សេងទៀត ដែលបង្កើតឡើងដោយការិយាល័យតម្កល់ ហើយពាក់ព័ន្ធនឹងលិខិតជូនដំណឹងនេះត្រូវចាត់ទុកជាកំណត់ត្រាសាធារណៈ ។

៣-បុគ្គលគ្រប់រូបមានសិទ្ធិពិនិត្យមើល និងថតចម្លងកំណត់ត្រាសាធារណៈដែលតម្កល់នៅការិយាល័យតម្កល់ដោយគ្មានការរើសអើងអ្វីឡើយ ។

**មាត្រា ៣៣.-**

១-ត្រូវចាត់ទុកថាលិខិតជូនដំណឹងដំបូងមានលក្ខណៈគ្រប់គ្រាន់ បើលិខិតជូនដំណឹងនេះ :

ក-កំណត់អត្តសញ្ញាណនិងចែងពីអាសយដ្ឋានរបស់កូនបំណុល ។

ខ-កំណត់អត្តសញ្ញាណម្ចាស់បំណុលដែលមានកិច្ចធានា ឬភ្នាក់ងាររបស់ម្ចាស់បំណុលដែលមានកិច្ចធានា និងអាសយដ្ឋានរបស់ម្ចាស់បំណុល ។

គ-ពណ៌នាអំពីទ្រព្យធានាដែលចុះក្នុងលិខិតជូនដំណឹងជាអក្សរខ្មែរ និងអក្សរឡាតាំង និងលេខអារ៉ាប់ ។ ក្រៅពីនេះលិខិតជូនដំណឹងត្រូវតែអធិប្បាយពីអចលនវត្ថុដែលពាក់ព័ន្ធ បើលិខិតជូនដំណឹងនេះចែងពីឈើឈរដែលត្រូវកាប់ ឬ រ៉ែដែលត្រូវជីកយក ឬបើទ្រព្យធានាជាចលនវត្ថុតាំងភ្ជាប់ ។

២-បុគ្គលមានសិទ្ធិតម្កល់លិខិតជូនដំណឹងដំបូង តែក្នុងករណីដែលកូនបំណុលអនុញ្ញាតឱ្យតម្កល់ដូចបានបញ្ជាក់ក្នុងកំណត់ត្រា ដែលកូនបំណុលបានបញ្ជាក់ការឯកភាព ។ កំណត់ត្រាបញ្ជាក់ការឯកភាព មិនចាំបាច់ចែងក្នុងលិខិតជូនដំណឹងឡើយ ។

៣-ការដែលកូនបំណុលចុះហត្ថលេខាលើកិច្ចព្រមព្រៀងប្រាតិភោគ មានន័យថាកូនបំណុលអនុញ្ញាតឱ្យតម្កល់លិខិតជូនដំណឹងដំបូង ឬវិសោធនកម្មដែលចែងពីទ្រព្យធានាដែលរៀបរាប់ក្នុងកិច្ចសន្យា និងផលនៃទ្រព្យធានា ទោះបីជាកិច្ចព្រមព្រៀងប្រាតិភោគចែងច្បាស់ ឬមិនបានចែងច្បាស់ពីផលនៃទ្រព្យធានាក្តី ។

៤-លិខិតជូនដំណឹងអាចត្រូវបានតម្កល់មុនចុះកិច្ចព្រមព្រៀងប្រាតិភោគ ឬមុនសិទ្ធិប្រាតិភោគភ្ជាប់ទៅនឹងទ្រព្យធានា ។

៥-លិខិតជូនដំណឹងដែលគោរពតាមលក្ខខណ្ឌតម្រូវភាគច្រើននៃមាត្រានេះត្រូវចាត់ទុកថាមានប្រសិទ្ធភាព ទោះបីជាមិនបានបំពេញលក្ខខណ្ឌទាំងស្រុងនៃមាត្រានេះក៏ដោយ

លើកលែងតែវិការៈនោះបង្កឱ្យមានការភ័ន្តច្រឡំខ្លាំង ។ លិខិតជូនដំណឹងដែលមិនបានចែងពីឈ្មោះកូនបំណុល ត្រូវចាត់ទុកថាជាលិខិតជូនដំណឹងដែលបង្កឱ្យមានការភ័ន្តច្រឡំខ្លាំង ។

មាត្រា ៣៤.-

១-ត្រូវចាត់ទុកថាលិខិតជូនដំណឹងចែងគ្រប់គ្រាន់ពីឈ្មោះ ឬនាមករណ៍របស់កូនបំណុលជាអក្សរខ្មែរ និងអក្សរឡាតាំង និងលេខអារ៉ាប់ កាលណា :

ក-កូនបំណុលជារូបវន្តបុគ្គលដែលមានឈ្មោះក្នុងកំណត់ត្រារបស់ក្រសួងមហាផ្ទៃ ហើយលិខិតជូនដំណឹងមានចុះអត្តលេខប្រាំបួនខ្ទង់ ដែលបោះពុម្ពលើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់សាមីជន ។

ខ-កូនបំណុលជារូបវន្តបុគ្គល ហើយមិនមែនជាពលរដ្ឋខ្មែរ លិខិតជូនដំណឹងត្រូវចុះឈ្មោះរបស់បុគ្គល ដូចដែលបោះពុម្ពលើលិខិតឆ្លងដែនរបស់សាមីជន និងឈ្មោះប្រទេសដែលចេញលិខិតឆ្លងដែននោះ ។

គ-កូនបំណុលជានីតិបុគ្គលដែលបង្កើតឡើង ឬ ទទួលស្គាល់តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា លិខិតជូនដំណឹងត្រូវចុះនាមករណ៍របស់កូនបំណុលដែលបានចុះក្នុងបញ្ជីពាណិជ្ជកម្ម ឬ នាមករណ៍ដែលច្បាប់ទទួលស្គាល់ ។

ឃ-កូនបំណុលជានីតិបុគ្គលបរទេស ដែលបង្កើតឡើងក្រៅព្រះរាជាណាចក្រកម្ពុជា ហើយមានសមត្ថភាពធ្វើអាជីវកម្មតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា បើលិខិតជូនដំណឹងបានចុះនាមករណ៍របស់កូនបំណុល ដូចបានចុះក្នុងបញ្ជីពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ។

ង-កូនបំណុលជានីតិបុគ្គលបរទេស ដែលមិនបានចុះក្នុងបញ្ជីពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ហើយលិខិតជូនដំណឹងនេះត្រូវចុះនាមករណ៍របស់កូនបំណុលដូចចុះក្នុងបញ្ជីពាណិជ្ជកម្មនៃប្រទេសកំណើតរបស់នីតិបុគ្គលបរទេសដែរ ។

២-លិខិតជូនដំណឹងដែលចែងគ្រប់គ្រាន់ពីឈ្មោះរបស់កូនបំណុល មិនអាចក្លាយទៅជាអនុប្បញ្ញត្តិភាពដោយសារការចែង ឬ មិនបានចែងពីពាណិជ្ជនាម ឬ ឈ្មោះផ្សេងទៀត

ROYAUME DU CAMBODGE
MINISTÈRE du PALAIS ROYAL

របស់កូនបំណុលឡើយ ។ លិខិតជូនដំណឹងដែលចែងតែពីពាណិជ្ជនាមរបស់កូនបំណុល មិនចាត់ទុកថាបានចែងគ្រប់គ្រាន់ពីឈ្មោះរបស់កូនបំណុលឡើយ ។

៣-លិខិតជូនដំណឹង អាចចែងពីឈ្មោះកូនបំណុលនិងម្ចាស់បំណុលមានកិច្ចធានាលើសពីមួយបាន ។

៤-ក្នុងករណីដែលលិខិតជូនដំណឹង មិនបានបញ្ជាក់ថាបុគ្គលជាភ្នាក់ងាររបស់ម្ចាស់បំណុលដែលមានកិច្ចធានា មិនប៉ះពាល់ដល់ភាពគ្រប់គ្រាន់នៃលិខិតជូនដំណឹងឡើយ ។

**មាត្រា ៣៥.–**

១-លិខិតជូនដំណឹងដែលបានតម្កល់ ត្រូវបន្តមានប្រសិទ្ធភាពលើទ្រព្យធានាដែលត្រូវបានលក់ ដោះដូរ ជួល ឬជម្រះចោលតាមវិធីដែលសិទ្ធិប្រាតិភោគបន្តមានអត្ថិភាព ទោះបីម្ចាស់បំណុលមានកិច្ចធានាបានដឹង ឬ យល់ព្រមនឹងការជម្រះចោលនេះក៏ដោយ ។

២-បើកូនបំណុលប្តូរឈ្មោះដែលធ្វើឱ្យលិខិតជូនដំណឹង ដែលបានតម្កល់បង្កការភ័ន្តច្រឡំខ្លាំង លិខិតជូនដំណឹងនេះមានប្រសិទ្ធភាព ដើម្បីបន្តសុក្រឹតភាពសិទ្ធិប្រាតិភោគលើទ្រព្យធានាដែលកូនបំណុលទទួលបានមុន ឬ ក្នុងរយៈពេលបួន(០៤)ខែ បន្ទាប់ពីការប្តូរឈ្មោះនេះ ។ លិខិតជូនដំណឹងនេះមានប្រសិទ្ធភាព ដើម្បីបន្តសុក្រឹតភាពសិទ្ធិប្រាតិភោគលើទ្រព្យធានាដែលកូនបំណុលទទួលបាន ក្នុងរយៈពេលលើសពីបួន(០៤)ខែ ក្រោយពីការប្តូរឈ្មោះនេះ តែក្នុងករណីដែលបានតម្កល់វិសោធនកម្មលើលិខិតជូនដំណឹង ដើម្បីកែតម្រូវឈ្មោះក្នុងរយៈពេលបួន(០៤)ខែបន្ទាប់ពីការប្តូរឈ្មោះនេះ ។

៣-លើកលែងតែប្រការដែលចែងពីការប្តូរឈ្មោះកូនបំណុលក្នុងចំណុចទី ២ ខាងលើ លិខិតជូនដំណឹងនេះបន្តមានប្រសិទ្ធភាព ទោះបីជាកាលៈទេសៈបានកែប្រែ និងបណ្តាលឱ្យលិខិតជូនដំណឹងបង្កការភ័ន្តច្រឡំខ្លាំង បន្ទាប់ពីការតម្កល់លិខិតជូនដំណឹងក៏ដោយ ។

**មាត្រា ៣៦.–**

១-លិខិតជូនដំណឹងមានប្រសិទ្ធភាព សម្រាប់រយៈពេលប្រាំ(០៥)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការតម្កល់ ។

២-លិខិតជូនដំណឹងដែលបានតម្កល់ត្រូវអស់ប្រសិទ្ធភាព នៅពេលដែលផុតរយៈពេលប្រាំ(០៥)ឆ្នាំ លើកលែងតែបុគ្គលបានតម្កល់លិខិតសុំបន្តមុនផុតរយៈពេលប្រាំ(០៥)ឆ្នាំ ។

៣-លិខិតជូនដំណឹងក្លាយទៅជាគ្មានប្រសិទ្ធភាព នៅពេលផុតរយៈពេលប្រាំ(០៥) ឆ្នាំ ហើយរាល់សិទ្ធិប្រាតិភោគដែលមានសុក្រឹតភាព តាមលិខិតជូនដំណឹងនេះក៏ក្លាយទៅជាគ្មានសុក្រឹតភាពដែរ លើកលែងតែសិទ្ធិប្រាតិភោគដែលមានប្រសិទ្ធភាពដោយមិនចាំបាច់តម្កល់លិខិតជូនដំណឹង ។

៤-បើសិទ្ធិប្រាតិភោគក្លាយទៅជាគ្មានសុក្រឹតភាពនៅពេលផុតរយៈពេល ត្រូវចាត់ទុកថាមិនដែលបានធ្វើសុក្រឹតកម្ម ចំពោះអ្នកទិញទ្រព្យធានាពីមុន ឬ អ្នកទិញទ្រព្យធានាបន្តបន្ទាប់ដែលបានបង់តម្លៃឡើយ ។

**មាត្រា ៣៧.-**

១-លិខិតជូនដំណឹងដំបូងអាចត្រូវកែប្រែដោយវិសោធនកម្មម្តង ឬ ច្រើនដង ។ វិសោធនកម្មត្រូវតែ :

ក-បញ្ជាក់ពីលិខិតជូនដំណឹងដំបូងតាមលេខតម្កល់ ។

ខ-បញ្ជាក់ពីម្ចាស់បំណុលដែលមានកិច្ចធានា ក្នុងលិខិតជូនដំណឹងដែលអនុញ្ញាតឱ្យមានវិសោធនកម្មនេះ ។

គ-បញ្ជាក់ថានេះជាវិសោធនកម្មលើលិខិតជូនដំណឹង ។

ឃ-ចែងពីព័ត៌មានចាំបាច់ទាំងអស់ ក្នុងលិខិតជូនដំណឹងដំបូងដោយចែងផ្ទុះបញ្ចាំងពីលិខិតជូនដំណឹងនេះទាំងស្រុងឡើងវិញ ។

២-បើវិសោធនកម្មដាក់បន្ថែមទ្រព្យធានា ដែលចែងក្នុងលិខិតជូនដំណឹង ឬ បន្ថែមកូនបំណុលទៅក្នុងលិខិតជូនដំណឹង លិខិតជូនដំណឹងនេះមានប្រសិទ្ធភាព បើកូនបំណុលអនុញ្ញាតឱ្យតម្កល់តាមកំណត់ត្រាដែលកូនបំណុលបានឯកភាព ។ ការដែលកូនបំណុលចុះហត្ថលេខាលើកិច្ចព្រមព្រៀងប្រាតិភោគមានន័យថា កូនបំណុលអនុញ្ញាតឱ្យតម្កល់វិសោធនកម្មចែងពីទ្រព្យធានាដែលចុះក្នុងកិច្ចព្រមព្រៀងប្រាតិភោគនិងផលនៃទ្រព្យធានា ទោះបីជាកិច្ចព្រមព្រៀងប្រាតិភោគចែងជាក់លាក់ ឬ មិនជាក់លាក់ពីផលនៃទ្រព្យធានាក៏ដោយ ។

៣-បើលិខិតជូនដំណឹងចែងពីម្ចាស់បំណុលដែលមានកិច្ចធានាលើសពីមួយ វិសោធនកម្មមានប្រសិទ្ធភាព ចំពោះតែម្ចាស់បំណុល ដែលមានកិច្ចធានាដែលអនុញ្ញាតឱ្យតម្កល់តាមកំណត់ត្រាដែលកូនបំណុលបានឯកភាពប៉ុណ្ណោះ ។

៤-វិសោធនកម្មបន្ថែមទ្រព្យធានា មានប្រសិទ្ធភាពលើទ្រព្យធានាដែលបន្ថែមនោះ គិតចាប់ពីកាលបរិច្ឆេទនៃការតម្កល់វិសោធនកម្ម ។

៥-វិសោធនកម្មបន្ថែមកូនបំណុល មានប្រសិទ្ធភាពលើកូនបំណុលដែលបន្ថែមនោះ គិតចាប់ពីកាលបរិច្ឆេទនៃការតម្កល់វិសោធនកម្ម ។

៦-វិសោធនកម្មក្រៅពីវិសោធនកម្មបន្ថែមទ្រព្យធានា ឬ បន្ថែមកូនបំណុលមានប្រសិទ្ធភាពតែក្នុងករណីដែលម្ចាស់បំណុលដែលមានកិច្ចធានា អនុញ្ញាតឱ្យតម្កល់តាមកំណត់ត្រាដែលកូនបំណុលបានឯកភាព ។

៧-វិសោធនកម្មគ្មានប្រសិទ្ធភាពទេ បើវិសោធនកម្មនេះចែងលុបចោលម្ចាស់បំណុលដែលមានកិច្ចធានាទាំងអស់ ដោយមិនបានចែងពីឈ្មោះម្ចាស់បំណុល ដែលមានកិច្ចធានាថ្មី ឬ ចែងលុបឈ្មោះកូនបំណុលទាំងអស់ និងមិនបានចែងពីឈ្មោះកូនបំណុល ដែលមិនបានបញ្ជាក់ក្នុងលិខិតជូនដំណឹងពីមុន ។

៨-បើមានម្ចាស់បំណុលដែលមានកិច្ចធានាលើសពីមួយ ក្នុងលិខិតជូនដំណឹងម្ចាស់បំណុលដែលមានកិច្ចធានាម្នាក់ៗ អាចអនុញ្ញាតឱ្យតម្កល់វិសោធនកម្មបាន ។

៩-វិសោធនកម្មដែលអនុញ្ញាតដោយម្ចាស់បំណុលដែលមានកិច្ចធានាម្នាក់ មិនប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បំណុលដែលមានកិច្ចធានាផ្សេងទៀត ដែលមានឈ្មោះក្នុងលិខិតជូនដំណឹងឡើយ ។

១០-ការតម្កល់វិសោធនកម្ម មិនធ្វើឱ្យរយៈពេលប្រសិទ្ធភាពនៃលិខិតជូនដំណឹងត្រូវកើនឡើងទេ ។

មាត្រា ៣៨.-

១-រយៈពេលប្រសិទ្ធភាពនៃលិខិតជូនដំណឹង អាចត្រូវបន្តដោយតម្កល់លិខិតសុំបន្តដែល :

ក-បញ្ជាក់ពីលេខតម្កល់នៃលិខិតជូនដំណឹងដំបូង ។

ខ-បញ្ជាក់ពីម្ចាស់បំណុលដែលមានកិច្ចធានា ក្នុងលិខិតជូនដំណឹងដែលអនុញ្ញាតឱ្យមានលិខិតសុំបន្តនេះ ។

គ-បញ្ជាក់ថាលិខិតជូនដំណឹងត្រូវបន្តប្រសិទ្ធភាព ចំពោះម្ចាស់បំណុលដែល

មានកិច្ចធានាដែលអនុញ្ញាតឱ្យតម្កល់ ។

២-ភាគីអាចតម្កល់លិខិតសុំបន្តសុពលភាព ក្នុងរយៈពេលប្រាំមួយ(០៦)ខែ មុនផុតរយៈពេលប្រាំ(០៥)ឆ្នាំ ដែលលិខិតជូនដំណឹងមានសុពលភាព ។

ក-ចាប់ពីពេលតម្កល់លិខិតសុំបន្ត លិខិតជូនដំណឹងត្រូវបន្តសុពលភាពនិងមានប្រសិទ្ធភាពសម្រាប់រយៈពេលប្រាំ(០៥)ឆ្នាំទៀត គិតចាប់ពីថ្ងៃដែលលិខិតជូនដំណឹងដំបូងត្រូវអស់ប្រសិទ្ធភាព ។

ខ-ប្រសិទ្ធភាពនេះត្រូវបន្តចំពោះតែម្ចាស់បំណុលដែលមានកិច្ចធានាដែលអនុញ្ញាតឱ្យតម្កល់លិខិតសុំបន្តប៉ុណ្ណោះ ។

គ-នៅពេលផុតរយៈពេលប្រាំ(០៥)ឆ្នាំ លិខិតជូនដំណឹងត្រូវអស់សុពលភាពចំពោះម្ចាស់បំណុលដែលមានកិច្ចធានា លើកលែងតែលិខិតសុំបន្តដែលអនុញ្ញាតដោយម្ចាស់បំណុលដែលមានកិច្ចធានាត្រូវបានតម្កល់មុនផុតរយៈពេលនេះ ។ ដើម្បីបន្តប្រសិទ្ធភាពលិខិតជូនដំណឹងតទៅទៀត ភាគីអាចតម្កល់លិខិតសុំបន្តសុពលភាពជាបន្តបន្ទាប់តាមរបៀបដូចបានចែងខាងលើនេះ ។

**មាត្រា ៣៩.-**

១-ប្រសិទ្ធភាពនៃលិខិតជូនដំណឹង អាចត្រូវបញ្ចប់ដោយការតម្កល់លិខិតសុំបញ្ចប់ដែល:

ក-បញ្ជាក់ពីលិខិតជូនដំណឹងដំបូងតាមលេខតម្កល់ ។

ខ-បញ្ជាក់ពីម្ចាស់បំណុលដែលមានកិច្ចធានា ក្នុងលិខិតជូនដំណឹងដែលអនុញ្ញាតឱ្យបញ្ចប់នេះ ។

គ-បញ្ជាក់ថាលិខិតជូនដំណឹងគ្មានប្រសិទ្ធភាព ចំពោះផលប្រយោជន៍របស់ម្ចាស់បំណុលដែលមានកិច្ចធានាដែលអនុញ្ញាតឱ្យបញ្ចប់ ។

២-ក្នុងរយៈពេលម្ភៃ(២០)ថ្ងៃ បន្ទាប់ពីម្ចាស់បំណុលដែលមានកិច្ចធានា បានទទួលការទាមទារជាលាយលក្ខណ៍អក្សរពីកូនបំណុល ម្ចាស់បំណុលដែលមានកិច្ចធានាត្រូវតម្កល់លិខិតសុំបញ្ចប់ ប្រសិនបើ:

ក-គ្មានជំពាក់កាតព្វកិច្ចប្រាតិភោគនិងគ្មានការសន្យាផ្តល់បុរេប្រទាន ការបង្កើត

កាតព្វកិច្ច ឬ ការផ្តល់តម្លៃតាមវិធីក្រៅពីនេះទេ ឬ

-កូនបំណុលមិនបានអនុញ្ញាតឱ្យតម្កល់លិខិតជូនដំណឹងដំបូង ឬ

-លិខិតជូនដំណឹងដែលចែងពីគណនី ឬ កិច្ចសន្យាលក់ដែលមានកិច្ចធានា ដែលត្រូវបានលក់ ប៉ុន្តែកូនបំណុលគណនី ឬ បុគ្គលដែលជំពាក់កាតព្វកិច្ច បានរំលត់កាតព្វកិច្ចរបស់ខ្លួនសព្វគ្រប់អស់ហើយ ។

៣-លិខិតសុំបញ្ចប់ អាចបញ្ចប់សិទ្ធិរបស់ម្ចាស់បំណុលដែលមានកិច្ចធានាក្នុងលិខិតជូនដំណឹង តែក្នុងករណីដែលម្ចាស់បំណុលមានកិច្ចធានា បានអនុញ្ញាតតាមរយៈកំណត់ត្រាដែលមានបញ្ជាក់ការឯកភាព ។ នៅពេលតម្កល់លិខិតសុំបញ្ចប់ ដែលមានប្រសិទ្ធភាព លិខិតជូនដំណឹងដែលពាក់ព័ន្ធនឹងលិខិតសុំបញ្ចប់នេះ ក្លាយទៅជាគ្មានប្រសិទ្ធភាពចំពោះម្ចាស់បំណុលដែលមានកិច្ចធានាដែលបានអនុញ្ញាតឱ្យតម្កល់ ។

មាត្រា ៤០.-

១-ការប្រគល់លិខិតជូនដំណឹងដំបូង វិសោធនកម្ម លិខិតសុំបន្ត ឬ លិខិតសុំបញ្ចប់ និងការស្នើសុំបង់ថ្លៃតម្កល់ ឬ ការទទួលកំណត់ត្រាដោយការិយាល័យតម្កល់ ត្រូវចាត់ទុកជាការតម្កល់ លើកលែងតែប្រការដែលមានចែងក្នុងវាក្យខណ្ឌទី ២ ខាងក្រោមនេះ ។

២-មិនចាត់ទុកថាមានការតម្កល់លិខិតជូនដំណឹងទេ បើកំណត់ត្រានេះត្រូវបានការិយាល័យតម្កល់បដិសេធ ក្នុងករណីដែល :

ក-លិខិតជូនដំណឹងដំបូងមិនបានផ្តល់ព័ត៌មានតាមច្បាប់តម្រូវ ។

ខ-វិសោធនកម្ម មិនបានផ្តល់ព័ត៌មានតាមច្បាប់តម្រូវ ឬវិសោធនកម្មបញ្ជាក់ពីលិខិតជូនដំណឹងដំបូងដែលផុតរយៈពេលមានប្រសិទ្ធភាព ។

គ-លិខិតសុំបន្តមិនបានបញ្ជាក់ពីលេខនៃលិខិតជូនដំណឹងដំបូង ឬ មិនបានប្រគល់ជូនក្នុងរយៈពេលប្រាំមួយ(០៦)ខែ ដែលច្បាប់នេះបានអនុញ្ញាត ឬ

ឃ-លិខិតសុំបញ្ចប់មិនបានបញ្ជាក់ពីលេខនៃលិខិតជូនដំណឹងដំបូង ។

៣-ការិយាល័យតម្កល់ មិនអាចបដិសេធមិនតម្កល់លិខិតជូនដំណឹងក្រៅពីមូលហេតុដែលចែងក្នុងវាក្យខណ្ឌទី ២ នៃមាត្រានេះឡើយ លើកលែងតែមានការស្នើសុំបង់ថ្លៃតម្កល់ដែលមានចែងនៅក្នុងច្បាប់កំណត់ ទើបការិយាល័យតម្កល់អាចបដិសេធបាន ។

ក-កំណត់ត្រារួមជាមួយថ្លៃសេវាតម្កល់ ដែលដាក់ជូនការិយាល័យតម្កល់ ប៉ុន្តែបើការិយាល័យតម្កល់បានបដិសេធ ដោយផ្អែកលើមូលហេតុក្រៅពីមូលហេតុដែលចែងក្នុងមាត្រានេះ ត្រូវចាត់ទុកថាកំណត់ត្រាដែលបានតម្កល់នោះមានប្រសិទ្ធភាព ប៉ុន្តែគ្មានអនុភាពលើអ្នកទិញទ្រព្យធានា ដែលបានបង់ថ្លៃដោយមានការជឿជាក់សមហេតុផលថាគ្មានកំណត់ត្រាណាតម្កល់ពីមុនទេ ។

ខ-បើការិយាល័យតម្កល់បដិសេធការទទួលតម្កល់ ការិយាល័យនេះត្រូវតែបញ្ជូនអង្គហេតុ និងមូលហេតុនៃការបដិសេធរបស់ខ្លួនភ្លាមៗជូនទៅបុគ្គលដែលបានដាក់ជូនកំណត់ត្រានេះ ។

៤-លិខិតជូនដំណឹងដែលបានតម្កល់ មានប្រសិទ្ធភាពតែក្នុងករណីដែលបានតម្កល់ដោយបុគ្គលដែលច្បាប់នេះអនុញ្ញាតឱ្យតម្កល់ ។

៥-ការជូនដំណឹងដែលអនុញ្ញាតដោយម្ចាស់បំណុលដែលមានកិច្ចធានាម្នាក់ ដែលមានឈ្មោះក្នុងលិខិតជូនដំណឹង មិនប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បំណុលមានកិច្ចធានាផ្សេងទៀត ដែលបញ្ជាក់ក្នុងលិខិតជូនដំណឹងឡើយ ។

៦-ការចម្លងនិទ្ទេសមិនបានត្រឹមត្រូវដោយការិយាល័យតម្កល់ មិនប៉ះពាល់ប្រសិទ្ធភាពនៃកំណត់ត្រាឡើយ ។

**មាត្រា ៤១.-**

១-បុគ្គលពាក់ព័ន្ធនៅក្នុងការតម្កល់លិខិតជូនដំណឹង អាចតម្កល់លិខិតសុំកែតម្រូវនៅការិយាល័យតម្កល់ ដើម្បីកែតម្រូវលិខិតជូនដំណឹងដែលមានចុះឈ្មោះរបស់ខ្លួន បើខ្លួនជឿថាកំណត់ត្រានោះមានកំហុស ឬ បានតម្កល់ដោយមិនត្រឹមត្រូវ ។

២-លិខិតសុំកែតម្រូវត្រូវតែ :

ក-បញ្ជាក់ពីកំណត់ត្រាដែលត្រូវកែតម្រូវ ដោយកំណត់ពីលេខតម្កល់នៃលិខិតជូនដំណឹងដំបូង ។

ខ-បញ្ជាក់ថាលិខិតនេះជាលិខិតសុំកែតម្រូវ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

គ-បញ្ជាក់ពីមូលហេតុដែលបុគ្គលសាមីជឿថា កំណត់ត្រានេះមិនត្រឹមត្រូវនិង ចង្អុលបង្ហាញពីវិធីដែលត្រូវកែតម្រូវកំហុស ឬបញ្ជាក់ពីមូលហេតុ ដែលខ្លួនជឿថាកំណត់ត្រានោះបានតម្កល់ដោយមិនត្រឹមត្រូវ ។

៣-ការតម្កល់លិខិតសុំកែតម្រូវ មិនប៉ះពាល់ដល់ប្រសិទ្ធភាពនៃលិខិតជូនដំណឹងឡើយ ។

**មាត្រា ៤២.-**

១-រាល់លិខិតជូនដំណឹងដែលខ្លួនទទួលតម្កល់ ការិយាល័យតម្កល់ត្រូវតែ :

ក-ដាក់លេខកូដពិសេសលើកំណត់ត្រាដែលបានតម្កល់ ។

ខ-បង្កើតសំណុំកំណត់ត្រាដែលមានចុះលេខកូដពិសេស កាលបរិច្ឆេទ និងពេលវេលានៃការតម្កល់ ។

គ-រក្សាទុកកំណត់ត្រាដែលបានតម្កល់សម្រាប់សាធារណជនពិនិត្យ ។

២-ការិយាល័យតម្កល់ត្រូវតែកត់ត្រាលិខិតជូនដំណឹងដំបូង ដោយចុះឈ្មោះកូនបំណុល និងត្រូវចុះកំណត់ត្រាទាំងអស់ ដែលពាក់ព័ន្ធនឹងលិខិតជូនដំណឹងដំបូង តាមរបៀបដែលយោងទៅរកលិខិតជូនដំណឹងដំបូង ។ ចំពោះលិខិតជូនដំណឹងដែលមានចែងពីលេខសេរីនៃយានយន្តមានលេខសេរី ការិយាល័យតម្កល់ត្រូវរក្សាទុកនិទ្ទេសលេខសេរីនោះ ។

៣-ការិយាល័យតម្កល់ត្រូវសម្រួលដល់ការស្វែងរកកំណត់ត្រាដោយប្រើឈ្មោះ និងលេខកូដរបស់កូនបំណុល ដែលបានចុះលើលិខិតជូនដំណឹងដំបូង ដែលពាក់ព័ន្ធនឹងកំណត់ត្រានេះនិងឯកសារតម្កល់ទាំងអស់ ដែលទាក់ទងគ្នានឹងលិខិតជូនដំណឹងដំបូង ។ ចំពោះលិខិតជូនដំណឹងដែលមានចែងពីលេខសេរីនៃយានយន្តដែលមានលេខសេរី ការិយាល័យតម្កល់ ត្រូវផ្តល់លទ្ធភាពដល់ការទាញកំណត់ត្រាមកប្រើតាមរយៈលេខសេរីនៃយានយន្តមានលេខសេរីនោះ ។

៤-ការិយាល័យតម្កល់ត្រូវរក្សាទុកកំណត់ត្រា ដែលអស់ប្រសិទ្ធភាពក្នុងរយៈពេលដប់(១០)ឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទផុតរយៈពេល ។

៥-មន្ត្រីនៃការិយាល័យតម្កល់មានអំណាចតែលើកិច្ចការរដ្ឋបាលប៉ុណ្ណោះ ។ មាតិកានៃលិខិតជូនដំណឹងត្រូវដកស្រង់ចេញពីកិច្ចព្រមព្រៀងឯកជនដែលច្បាប់នេះអនុញ្ញាតនិង

ROYAUME DU CAMBODGE MINISTÈRE DU PALAIS ROYAL

ច្បាប់ដទៃទៀតនៃព្រះរាជាណាចក្រកម្ពុជា ដែលមិនតម្រូវឱ្យមានការឯកភាព ឬការយល់ព្រមពីបុគ្គលណាក្រៅពីភាគីនៃកិច្ចព្រមព្រៀងឡើយ ។ ការិយាល័យតម្កល់មិនមានអំណាចក្នុងការពិនិត្យលិខិតជូនដំណឹង ដើម្បីកំណត់ពីភាពគ្រប់គ្រាន់សុពលភាព ឬបញ្ជាក់ថាមានតម្លៃតាមច្បាប់ឡើយ ។

**មាត្រា ៤៣.-**

១-ការិយាល័យតម្កល់ត្រូវតែផ្តល់ជូនបុគ្គលដែលស្នើសុំ នូវព័ត៌មានដូចខាងក្រោមនេះ :

ក-រាល់លិខិតជូនដំណឹងដែលចែងពីកូនបំណុល នឹងនៅមានប្រសិទ្ធភាពចំពោះម្ចាស់បំណុលដែលមានកិច្ចធានាទាំងអស់ ទោះបីជាការិយាល័យនេះមាន ឬ នឹងទទួលបានព័ត៌មាននោះនាកាលបរិច្ឆេទ និងពេលវេលាដែលការិយាល័យតម្កល់បានកំណត់ក៏ដោយ ។

ខ-លេខកូដឯកសារ កាលបរិច្ឆេទ និងពេលវេលានៃការតម្កល់លិខិតជូនដំណឹងនីមួយៗ ។

គ-ឈ្មោះ និងអាសយដ្ឋានរបស់ម្ចាស់បំណុល ដែលមានកិច្ចធានាដែលចុះលើលិខិតជូនដំណឹងនីមួយៗ ។

ឃ-សេចក្តីអធិប្បាយពីទ្រព្យធានាក្នុងលិខិតជូនដំណឹងឬវិសោធនកម្មនីមួយៗ។

ង-លេខកូដឯកសារ កាលបរិច្ឆេទ និងពេលនៃការតម្កល់កំណត់ត្រានីមួយៗដែលពាក់ព័ន្ធនឹងលិខិតជូនដំណឹងនីមួយៗ និងកំណត់ត្រាដែលជាលិខិតសុំបន្ត លិខិតសុំកែតម្រូវ ឬ លិខិតសុំបញ្ចប់ ។

២-បុគ្គលអាចស្នើសុំរកកំណត់ត្រានៅការិយាល័យតម្កល់ តាមលក្ខណៈវិនិច្ឆ័យណាមួយដូចខាងក្រោមនេះ :

-លេខតម្កល់នៃលិខិតជូនដំណឹង ឬ

-លេខស៊េរីនៃយានយន្តមានលេខស៊េរី ឬ

-លេខអត្តសញ្ញាណប័ណ្ណរបស់កូនបំណុលជារូបវន្តបុគ្គល ដែលមានសញ្ជាតិ

ឈ្មោះរបស់កូនបំណុលដែលជានីតិបុគ្គល ដែលមានសញ្ជាតិខ្មែរ ។

៣-ការិយាល័យតម្កល់ អាចផ្តល់កំណត់ត្រាតាមគ្រប់មធ្យោបាយ ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួន ។ ប៉ុន្តែបើមានការស្នើសុំការិយាល័យតម្កល់ ត្រូវផ្តល់កំណត់ត្រាដោយចេញលិខិតបញ្ជាក់ដែលអាចប្រើជាភស្តុតាង ក្នុងតុលាការនៃព្រះរាជាណាចក្រកម្ពុជា ដោយមិនចាំបាច់មានភស្តុតាងក្រៅពីឯកសារផ្ទាល់មកបញ្ជាក់បន្ថែមឡើយ ។

**មាត្រា ៤៤.-**

១-ថ្វីបើមានបទប្បញ្ញត្តិក្នុងមាត្រា ៣០ ក៏ដោយ បើទ្រព្យធានាជាចលនវត្ថុតាំងភ្ជាប់រ៉ែដែលនឹងត្រូវជីកយក ឬឈើឈរដែលនឹងត្រូវកាប់ ត្រូវតម្កល់លិខិតជូនដំណឹង ដើម្បីធ្វើសុក្រឹតកម្មសិទ្ធិប្រាតិភោគនៅការិយាល័យចុះបញ្ជី ដែលបានបង្កើតឡើងតាមច្បាប់ភូមិបាលជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

២-លិខិតជូនដំណឹងដែលតម្កល់តាមវាក្យខណ្ឌនេះ ត្រូវអនុលោមតាមវិធានដែលកំណត់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

**មាត្រា ៤៥.-**

១-ថ្លៃសេវាសម្រាប់ការតម្កល់លិខិតជូនដំណឹងដំបូង លិខិតសុំបន្ត លិខិតសុំបញ្ចប់ ឬ លិខិតសុំកែតម្រូវ ថ្លៃសេវារៀបចំរបាយការណ៍ស្រាវជ្រាវដែលមានការបញ្ជាក់ ឬសេវាផ្សេងៗទៀត ត្រូវបង់តាមការកំណត់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ។

២-ទោះបីមានបញ្ញត្តិក្នុងចំណុចទី ១ ក៏ដោយ ច្បាប់នេះមិនតម្រូវឱ្យមានថ្លៃសេវាកម្មសម្រាប់របាយការណ៍ស្រាវជ្រាវរក ដែលបុគ្គលគ្រប់រូបទទួលបានពីការប្រើប្រាស់សេវាកម្មអេឡិចត្រូនិករបស់ការិយាល័យតម្កល់ឡើយ ។

៣-ច្បាប់នេះមិនតម្រូវឱ្យមានថ្លៃសេវាកម្មណាផ្សេងពីថ្លៃសេវាកម្មដែលកំណត់ខាងលើនេះឡើយ ។

## ជំពូកទី ៤

## ការអនុវត្ត

**មាត្រា ៤៦.-**

១-ភាគីនៃកិច្ចព្រមព្រៀងប្រាតិភោគ មានសេរីភាពក្នុងការកំណត់ពីការមិនសងបំណុលក្នុងកិច្ចសន្យារបស់ខ្លួន ។

២-នៅពេលកូនបំណុលមិនសងបំណុល ម្ចាស់បំណុលដែលមានកិច្ចធានាត្រូវមាន :

ក-សិទ្ធិកាន់កាប់ ឬ គ្រប់គ្រងទ្រព្យធានាតាមសិទ្ធិរបស់ខ្លួន ទោះបីជាកិច្ចព្រមព្រៀងប្រាតិភោគគ្មានចែងពីការកាន់កាប់ ឬការត្រួតត្រាក៏ដោយ ។

ខ-សិទ្ធិ និងដំណោះស្រាយដែលមានចែងក្នុងច្បាប់នេះ ។

គ-សិទ្ធិ និងដំណោះស្រាយដែលមានចែងក្នុងកិច្ចព្រមព្រៀងប្រាតិភោគ ។

ឃ-សិទ្ធិ និងដំណោះស្រាយដែលមានចែងក្នុងច្បាប់ផ្សេងទៀត ។

៣-ម្ចាស់បំណុលដែលមានកិច្ចធានាអាចប្រើសិទ្ធិណាមួយ ឬ ទាំងអស់ដែលខ្លួនមានក្នុងពេលជាមួយគ្នាបាន ។

៤-បើទ្រព្យធានាជាគណនីឬទ្រព្យអរូបីផ្សេងទៀត ម្ចាស់បំណុលដែលមានកិច្ចធានាអាចប្រើសិទ្ធិលើគណនី ឬទ្រព្យអរូបីនោះដោយមិនចាំបាច់ប្តឹងទៅតុលាការ ប៉ុន្តែត្រូវគោរពតាមបទប្បញ្ញត្តិនៃច្បាប់នេះ ដែលចែងពីអនុប្បទានសិទ្ធិឬសិទ្ធិប្រមូលបំណុល ។

៥-បើទ្រព្យធានាជាឯកសារ ម្ចាស់បំណុលដែលមានកិច្ចធានាអាចប្រើសិទ្ធិលើឯកសារ ឬ ចំពោះទំនិញដែលបានចែងក្នុងឯកសារក៏បាន ។

៦-នៅពេលកូនបំណុលមិនសងបំណុល ម្ចាស់បំណុលដែលមានកិច្ចធានាមានសិទ្ធិសុំសេចក្តីសម្រេចកិច្ចការប្រញាប់ពីតុលាការ ដែលអនុញ្ញាតឱ្យ ម្ចាស់បំណុលមានកិច្ចធានាកាន់កាប់ ឬ គ្រប់គ្រងលើទ្រព្យធានា ។

៧-កាលណាម្ចាស់បំណុលមានកិច្ចធានា បានទទួលសេចក្តីសម្រេចឱ្យកាន់កាប់អាទិភាពនៃការអនុវត្តសេចក្តីសម្រេចនេះ ត្រូវគិតចាប់ពីកាលបរិច្ឆេទតម្កល់លិខិតជូនដំណឹង ឬ សុក្រឹតកម្មនៃសិទ្ធិប្រាតិភោគ គឺយកកាលបរិច្ឆេទណាមួយដែលកើតឡើងមុន ។

CABINET DU PALAIS ROYAL

៨-ម្ចាស់បំណុលដែលមានកិច្ចធានា អាចទិញទ្រព្យធានាដែលប្រកាសលក់ដេញថ្លៃបាន ។

**មាត្រា ៤៧.-**

១-នៅពេលកូនបំណុលមិនសងបំណុលក្នុងគណនី ឬ សិទ្ធិទទួលការបង់ប្រាក់ផ្សេងទៀត ម្ចាស់បំណុលដែលមានកិច្ចធានា អាចប្រើសិទ្ធិរបស់ខ្លួនបានដោយផ្ទាល់ចំពោះគណនី ។

២-នៅពេលកូនបំណុលមិនសងបំណុលក្នុងគណនី កិច្ចសន្យាលក់ដែលមានកិច្ច-ធានា ឬសិទ្ធិទទួលការបង់ប្រាក់ផ្សេងទៀត ឬ នៅពេលដែលកូនបំណុលបានឯកភាព ម្ចាស់បំណុលដែលមានកិច្ចធានា មានសិទ្ធិជូនដំណឹងអំពីសិទ្ធិរបស់ខ្លួន ទៅកូនបំណុលនៃគណនី ឬ ភាគីកូនបំណុល ដើម្បីឱ្យបង់ប្រាក់ជូនម្ចាស់បំណុលដែលមានកិច្ចធានា និងគ្រប់គ្រងលើផលនៃទ្រព្យធានា ។

៣-បើសិទ្ធិប្រាតិភោគធានានូវបំណុល ម្ចាស់បំណុលដែលមានកិច្ចធានាត្រូវប្រគល់ទឹកប្រាក់ដែលប្រមូលបានដែលលើសពីបំណុលឱ្យទៅកូនបំណុល ។ កូនបំណុលត្រូវទទួលខុសត្រូវសងប្រាក់សមតុល្យរវាងប្រាក់បំណុលនិងប្រាក់ដែលប្រមូលបាន លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះ ។

៤-បើប្រតិបត្តិការជាការលក់គណនី ឬ កិច្ចសន្យាលក់ដែលមានកិច្ចធានាកូនបំណុលគ្មានសិទ្ធិលើទឹកប្រាក់ដែលលើសពីបំណុល និងគ្មានការទទួលខុសត្រូវចំពោះទឹកប្រាក់ដែលនៅខ្វះទេ លើកលែងតែកិច្ចព្រមព្រៀងប្រាតិភោគចែងផ្ទុយពីនេះ ។

៥-ម្ចាស់បំណុលដែលមានកិច្ចធានា អាចអនុវត្តតាមមាត្រានេះដោយមិនចាំបាច់ប្រើនីតិវិធីតុលាការក៏បាន ។

**មាត្រា ៤៨.-**

១-នៅពេលកូនបំណុលមិនសងបំណុល ម្ចាស់បំណុលមានកិច្ចធានាមានសិទ្ធិកាន់កាប់ ឬគ្រប់គ្រងទ្រព្យធានាដោយមិនចាំបាច់ប្ដឹងទៅតុលាការ បើកូនបំណុលបានឯកភាពជាលាយលក្ខណ៍អក្សរបន្ទាប់ពីកូនបំណុលមិនបានសងបំណុល ។

២-នៅពេលកូនបំណុលមិនសងបំណុល ម្ចាស់បំណុលមានកិច្ចធានាមានសិទ្ធិប្ដឹងសុំសេចក្ដីសម្រេចកិច្ចការប្រញាប់ ឬ ការបញ្ជាពិសេសពីតុលាការដែលអនុញ្ញាតឱ្យម្ចាស់បំណុលមានកិច្ចធានាកាន់កាប់ ឬ គ្រប់គ្រងទ្រព្យធានា ។

ក-សវនាការត្រូវផ្ដោតតែលើបញ្ហាដែលពាក់ព័ន្ធ នឹងកិច្ចព្រមព្រៀងប្រាតិភោគដែលចែងពីទ្រព្យធានា ហើយត្រូវមានការខកខានមិនបានសងបំណុលយ៉ាងតិចមួយលើក ។

ខ-ក្នុងករណីដែលត្រូវការសេវាកម្មរបស់អាជ្ញាសាលា ឬ មន្ត្រីដទៃទៀតជាចាំបាច់ ដើម្បីដកហូតទ្រព្យធានាពីកូនបំណុល ម្ចាស់បំណុលត្រូវបង់ថ្លៃសេវាជាប្រាក់រៀលតាមការកំណត់រួមរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងយុត្តិធម៌ ។

៣-បើមានចែងក្នុងកិច្ចព្រមព្រៀងប្រាតិភោគ ម្ចាស់បំណុលមានកិច្ចធានាអាចតម្រូវឱ្យកូនបំណុលផ្ដុំតម្លើងទ្រព្យធានា និងរៀបចំឱ្យហើយស្រេចសម្រាប់ម្ចាស់បំណុលមានកិច្ចធានានៅកន្លែងដែលសមស្រប និងងាយស្រួលដល់ភាគីទាំងពីរដែលម្ចាស់បំណុលមានកិច្ចធានាជាអ្នកកំណត់ ។

៤-ម្ចាស់បំណុលមានកិច្ចធានា អាចទុកដាក់ឧបករណ៍មិនឱ្យអ្នកផ្សេងប្រើប្រាស់បានដោយគ្មានផ្លាស់ប្ដូរទីតាំងរបស់វា ហើយអាចជម្រះចោលទ្រព្យធានានេះនៅមណ្ឌលអាជីវកម្ម ឬ លំនៅស្ថានរបស់កូនបំណុល ឬទីកន្លែងផ្សេងទៀតដែលរកឃើញទ្រព្យធានា ។

**មាត្រា ៤៩.-**

១-បន្ទាប់ពីកូនបំណុលមិនសងបំណុល ម្ចាស់បំណុលមានកិច្ចធានាអាចលក់ ជួល ផ្ដល់តាមអាជ្ញាប័ណ្ណ ឬ ជម្រះចោលទ្រព្យធានាណាមួយ ឬ ទាំងអស់ក៏បាន ។

២-ការជម្រះចោលទ្រព្យធានា អាចធ្វើឡើងជាសាធារណៈ ឬ ជាឯកជន ហើយអាចធ្វើឡើងតាមកិច្ចសន្យាមួយ ឬ ច្រើនក៏បាន ។

៣-ការជម្រះចោលនេះអាចធ្វើឡើងតាមឯកតា ឬ ជាកញ្ចប់ និងនៅពេលវេលា ទីកន្លែង និងតាមលក្ខខណ្ឌដែលស្របតាមកាតព្វកិច្ចរបស់ម្ចាស់បំណុលមានកិច្ចធានាដែលកំណត់ក្នុងច្បាប់នេះ ។

៤- ម្ចាស់បំណុលមានកិច្ចធានា ត្រូវផ្តល់ជូនកូនបំណុលនូវដំណឹងសមស្របអំពីពេលវេលា និងទីកន្លែងនៃការលក់ឡាយឡុងជាសាធារណៈ ឬ ពេលវេលាដែលត្រូវលក់ជាឯកជន ឬការជម្រះចោលដែលបានគ្រោងទុក លើកលែងតែទ្រព្យធានាដែលងាយផុយរលួយ ឬ បង្ហាញពីការធ្លាក់ចុះតម្លៃយ៉ាងឆាប់រហ័ស ។ កូនបំណុលអាចលះបង់សិទ្ធិក្នុងការទទួលព័ត៌មាននេះបាន ។

៥- ម្ចាស់បំណុលដែលមានកិច្ចធានា ត្រូវជូនដំណឹងដល់ម្ចាស់បំណុលដែលមានកិច្ចធានាផ្សេងទៀត ដែលបានធ្វើកំណត់ត្រាជាលាយលក្ខណ៍អក្សរ ដែលបញ្ជាក់ពីសិទ្ធិរបស់គេលើទ្រព្យធានាមកឱ្យម្ចាស់បំណុលដែលមានកិច្ចធានា ។

៦- ម្ចាស់បំណុលដែលមានកិច្ចធានា អាចទិញទ្រព្យធានាដែលលក់ឡាយឡុងជាសាធារណៈ ឬ ជាឯកជនបាន ។

មាត្រា ៥០.-

១- ផលនៃការជម្រះទ្រព្យធានា ត្រូវយកមកប្រើប្រាស់តាមលំដាប់ដូចខាងក្រោមនេះ :

ក- សងថ្លៃចំណាយសមស្រប ដែលកើតឡើងពីការទទួលយកការកាន់កាប់ ការរៀបចំជម្រះទ្រព្យធានា និងការជម្រះទ្រព្យធានា រាប់បញ្ចូលទាំងថ្លៃចំណាយសមស្របសម្រាប់មេធាវី និងថ្លៃចំណាយរឿងក្តី ដែលម្ចាស់បំណុលមានកិច្ចធានាបានចំណាយ ។

ខ- ទូទាត់បំណុលដែលធានាដោយសិទ្ធិប្រាតិភោគ ។

គ- ទូទាត់បំណុលដែលធានាដោយសិទ្ធិប្រាតិភោគ ក្នុងលំដាប់បន្ទាប់លើទ្រព្យធានា បើមានការទាមទារជាលាយលក្ខណ៍អក្សរ មុនពេលបញ្ចប់ការបែងចែកផលនៃទ្រព្យធានា ហើយអ្នកកាន់កាប់សិទ្ធិប្រាតិភោគបន្ទាប់នេះ បានផ្តល់ភស្តុតាងសមស្របពីផលប្រយោជន៍របស់ខ្លួន ។

ឃ- ទូទាត់បំណុលគ្មានទ្រព្យធានាដែលបានទទួលស្គាល់ ។

២- ម្ចាស់បំណុលដែលមានកិច្ចធានា ត្រូវប្រគល់ទឹកប្រាក់ដែលលើសពីបំណុលទៅឱ្យកូនបំណុល ហើយកូនបំណុលត្រូវទទួលខុសត្រូវសងទឹកប្រាក់ដែលខ្វះ លើកលែងតែមានកិច្ចព្រមព្រៀងផ្សេងពីនេះ ។

៣-កាលណាទ្រព្យធានា ត្រូវបានជម្រះចោលដោយម្ចាស់បំណុលដែលមានកិច្ចធានា បន្ទាប់ពីកូនបំណុលមិនសងបំណុល ៖

ក-ការជម្រះចោលនេះជាការផ្ទេរសិទ្ធិទាំងអស់ លើទ្រព្យធានាឱ្យទៅអ្នកទិញ ដែលបានបង់ថ្លៃ ហើយរំលត់សិទ្ធិប្រាតិភោគ និងសិទ្ធិប្រាតិភោគបន្ទាប់ ឬ ឯកសិទ្ធិផ្សេងទៀត បើអ្នកទិញបានទិញដោយសុចរិត និង

ខ-មន្ត្រីចុះបញ្ជីនៃការិយាល័យចុះបញ្ជី ដែលរក្សាទុកកំណត់ត្រាកម្មសិទ្ធិលើទ្រព្យធានាដូចជាមន្ត្រីចុះបញ្ជីសិទ្ធិកម្ម សិទ្ធិយានយន្តដែលមានលេខស៊េរី ត្រូវចេញប័ណ្ណកម្មសិទ្ធិថ្មីជូនអ្នកទិញដែលបានបង់តម្លៃ ហើយបើមានការស្នើសុំពីមន្ត្រីចុះបញ្ជី ម្ចាស់បំណុលដែលមានកិច្ចធានា ត្រូវផ្តល់ការអនុញ្ញាតឱ្យចេញប័ណ្ណកម្មសិទ្ធិថ្មី តាមរយៈសេចក្តីសម្រេចរបស់តុលាការដែលបង្គាប់ឱ្យម្ចាស់បំណុលកាន់កាប់ ឬកិច្ចព្រមព្រៀងលាយលក្ខណ៍អក្សររបស់កូនបំណុលដែលប្រគល់ ទ្រព្យធានាឱ្យម្ចាស់បំណុលកាន់កាប់ ដែលកូនបំណុលចុះហត្ថលេខា បន្ទាប់ពីការមិនសងបំណុល ។

**មាត្រា ៥១.-**

១-បន្ទាប់ពីការមិនសងបំណុល ម្ចាស់បំណុលមានកិច្ចធានា អាចស្នើសុំឃាត់ទុកទ្រព្យធានា ដើម្បីឱ្យមានការទូទាត់កាតព្វកិច្ចមួយផ្នែក ឬ ទាំងស្រុងបាន ។

២-ម្ចាស់បំណុលមានកិច្ចធានាត្រូវធ្វើការស្នើសុំនេះទៅកូនបំណុល និង ម្ចាស់បំណុលដែលមានកិច្ចធានាផ្សេងទៀត ដែលបានធ្វើការទាមទារជាលាយលក្ខណ៍អក្សរមកម្ចាស់បំណុលដែលមានកិច្ចធានា ហើយបញ្ជាក់ថាខ្លួនមានផលប្រយោជន៍ក្នុងទ្រព្យធានានេះ ។

៣-បើម្ចាស់បំណុលដែលមានកិច្ចធានា បានទទួលការជំទាស់ជាលាយលក្ខណ៍អក្សរពីបុគ្គលដែលមានសិទ្ធិទទួលលិខិតជូនដំណឹងក្នុងរយៈពេលម្ភៃ(២០)ថ្ងៃបន្ទាប់ពីបានធ្វើលិខិតជូនដំណឹង ម្ចាស់បំណុលដែលមានកិច្ចធានាត្រូវតែជម្រះចោលទ្រព្យធានាតាមបទ-ប្បញ្ញត្តិនៃជំពូកនេះ ។

៤-បើគ្មានការជំទាស់ក្នុងរយៈពេលម្ភៃ(២០)ថ្ងៃទេ ម្ចាស់បំណុលដែលមានកិច្ចធានា អាចឃាត់ទុកទ្រព្យធានា ដើម្បីទូទាត់កាតព្វកិច្ចរបស់កូនបំណុលស្របតាមការស្នើសុំ ។

មាត្រា ៥២.-

១-លើកលែងតែមានការព្រមព្រៀងលាយលក្ខណ៍អក្សរផ្ទុយពីនេះ បន្ទាប់ពីការមិនសងបំណុល កូនបំណុលឬម្ចាស់បំណុលដែលមានកិច្ចធានាផ្សេងទៀត អាចលោះយកទ្រព្យធានាដោយអនុវត្តកាតព្វកិច្ចទាំងអស់ ដែលធានាដោយទ្រព្យធានានេះ និងចេញថ្លៃចំណាយសមស្របដែលម្ចាស់បំណុលដែលមានកិច្ចធានាបានចាយក្នុងការកាន់កាប់ និង ជួសជុលទ្រព្យធានាសម្រាប់ជម្រះចោល រួមបញ្ចូលទាំងថ្លៃសេវាមេធាវី និងចំណាយសមស្របក្នុងរឿងក្តី ។

២-ការលោះយកទ្រព្យធានា ត្រូវតែធ្វើឡើងមុនពេលម្ចាស់បំណុលដែលមានកិច្ចធានាជម្រះចោលទ្រព្យធានា ឬ មុនពេលម្ចាស់បំណុលដែលមានកិច្ចធានាចុះកិច្ចសន្យាដើម្បីជម្រះចោលទ្រព្យធានា ឬ មុនពេលដែលកាតព្វកិច្ចត្រូវបានរំលត់ ។

មាត្រា ៥៣.-

១-បើម្ចាស់បំណុលមានកិច្ចធានា មិនគោរពតាមលក្ខខណ្ឌតម្រូវនៃជំពូកនេះ តុលាការអាចបង្គាប់ ឬ ហាមឃាត់ការជម្រះចោលទ្រព្យធានាដោយអនុលោមតាមបញ្ញត្តិ និងលក្ខខណ្ឌសមស្រប ។

២-ម្ចាស់បំណុលមានកិច្ចធានាត្រូវតែអនុវត្តតាមគោលការណ៍ពាណិជ្ជកម្ម ដែលសមស្របជានិច្ចក្នុងការជម្រះចោលទ្រព្យធានា ។

៣-បើទ្រព្យធានាត្រូវបានជម្រះចោលរួចហើយ កូនបំណុល ឬ បុគ្គលដែលមានសិទ្ធិទទួលព័ត៌មាន ឬបុគ្គលដែលបានជូនដំណឹងពីសិទ្ធិប្រាតិភោគរបស់ខ្លួនទៅម្ចាស់បំណុលដែលមានកិច្ចធានាមុនការជម្រះចោលទ្រព្យនេះ មានសិទ្ធិទារសំណងពីម្ចាស់បំណុលដែលមានកិច្ចធានាចំពោះការខាតបង់ ដែលបណ្តាលមកពីការមិនគោរពច្បាប់នេះ ។

៤- មិនត្រូវចាត់ទុកថា ការលក់មិនស្របតាមគោលការណ៍ពាណិជ្ជកម្មឡើយ បើគ្រាន់តែដោយសារការលក់នេះអាចនឹងទទួលតម្លៃខ្ពស់ជាង បើលក់នៅពេលវេលាផ្សេង ឬតាមវិធីផ្សេងពីវិធីដែលកំណត់ដោយម្ចាស់បំណុលដែលមានកិច្ចធានា ។

4

ROYAUME DU CAMBODGE
GREFFE DU PALAIS ROYAL

46

៥- ការលក់នឹងត្រូវចាត់ទុកថាស្របតាមគោលការណ៍ពាណិជ្ជកម្ម បើម្ចាស់បំណុលដែលមានកិច្ចធានា បានជម្រះចោលទ្រព្យធានាស្របតាមទម្លាប់ពាណិជ្ជកម្មរវាងពាណិជ្ជករ ដែលធ្វើអាជីវកម្មទ្រព្យដែលមានប្រភេទដូចគ្នានឹងទ្រព្យធានា ។

៦- បើវិធីជម្រះចោលទ្រព្យធានាត្រូវបានឯកភាពដោយតុលាការ ការជម្រះចោលត្រូវចាត់ទុកថា ស្របតាមគោលការណ៍ពាណិជ្ជកម្មទាំងស្រុង ប៉ុន្តែច្បាប់នេះមិនតម្រូវឱ្យមានការឯកភាពនេះជាចាំបាច់ឡើយ ។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**មាត្រា ៥៤.-**

បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥៥.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២៤ ខែឧសភា ឆ្នាំ ២០០៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

ចល.០៧០៥.២១១ **នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
**ហត្ថលេខា**
**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
**ហត្ថលេខា**
**ចម ប្រសិទ្ធ**

លេខៈ ២០៨៤ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ២០០៧
អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល
ស៊ុន ចិនកេន

43/43